# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម




Asian International Justice Initiative (AIJI), a project of East-West Center and UC Berkeley War Crimes Studies Center

*គិតទៅទ្រឹស្តី និងការអនុវត្តន៍*

*"ជីកស្មៅត្រូវជីកទាំងឫស ពិតជាត្រឹមត្រូវមែន។"*[1]

មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី លោក **ពេជ អង្គ**

សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី D22/3129

## ផ្នែកទី១៖ ទិដ្ឋភាពទូទៅ

នីតិវិធីសវនាការ បានចាប់ផ្តើមសាជាថ្មីនៅសប្តាហ៍នេះ ដោយយោងទៅតាមការកែសម្រួលកាលវិភាគដែលបានកំណត់ដោយអង្គជំនុំជម្រះ បន្ទាប់ពីមានការសម្រាកដោយមិនបានគិតទុកជាមុននៅសប្តាហ៍មុននេះ ដោយហេតុថា ជនជាប់ចោទលោក **នួន ជា** និងលោក **ខៀវ សំផន**[2] មានបញ្ហាសុខភាព ហើយត្រូវបញ្ជូនទៅមន្ទីរពេទ្យជាបន្ទាន់។ លោកប្រធានអង្គជំនុំជម្រះ **និល ណុន** បានពន្យល់ថា អង្គជំនុំជម្រះមិនអាចធ្វើសវនាការលើការស្តាប់សក្ខីកម្មផ្ទាល់មាត់[3] ចំពោះសវនាការលើឯកសារដែលបានកំណត់ធ្វើនៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ តែនឹងត្រូវលើកទៅធ្វើនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៣ ជំនួសវិញ។ សហព្រះរាជអាជ្ញា និងភាគីដើមបណ្តឹងរដ្ឋប្បវេណី នឹងធ្វើបទបង្ហាញនូវឯកសារនានាដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា ការជម្លៀសប្រជាពលរដ្ឋដោយបង្ខំក្នុងដំណាក់កាលទី១ និងទី២ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិជ្រៃ។ មេធាវីការពារក្តីមានឱកាសជាច្រើនក្នុងការឆ្លើយតបទៅនឹងឯកសារ ដែលបានដាក់បង្ហាញដោយសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី។ បញ្ហាមួយផ្សេងទៀតដែលត្រូវបានលើកឡើងក្នុងសប្តាហ៍នេះ គឺបញ្ហាបន្តអំពីផ្នែកសុខភាព និងផ្លូវកាយរបស់លោក **អៀង សារី**។

## ផ្នែកទី២ ៖ សវនាការលើឯកសារ

នីតិវិធីនៅសប្តាហ៍នេះ ទាក់ទងតែមួយគត់ទៅនឹងការដាក់បង្ហាញឯកសារ។ ផ្នែកនៃរបាយការណ៍នេះ ត្រូវបានរៀបចំឡើងដោយផ្អែកលើកាលវិភាគ ដែលបានកំណត់ដោយអនុស្សរណៈរបស់អង្គជំនុំជម្រះតុលាការដំបូង ចេញនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣។[4] ពីរថ្ងៃដំបូងនៃសវនាការនៅសប្តាហ៍នេះ វាហាក់ដូចជាមិនច្បាស់ទាល់តែសោះ ថាតើអង្គជំនុំជម្រះតុលាការដំបូងមានបំណងបង្ហាញឯកសារ និងការដាក់សំណើផ្សេងៗទៀតតាមរបៀបណានោះទេ។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញា បានដាក់បង្ហាញឯកសារជាច្រើន។ ក្រុមការពារក្តីបានលើកឡើងពីការជំទាស់ជាច្រើន ដែលស្រដៀងនឹងការតវ៉ារបស់ពួកគេនៅក្នុងសវនាការលើឯកសារកាលពីឆ្នាំមុន[5] ហើយព្រះរាជអាជ្ញា និងសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានយោងទៅលើសេចក្តីសម្រេចមុនៗលើបញ្ហាទាំងនេះ ដើម្បីជំទាស់តបនឹងក្រុមការពារក្តីវិញ។

### ក. ដំណាក់កាលដំបូងនៃការស្តាប់សវនាការលើឯកសារ

នៅក្នុងដំណាក់កាលដំបូងនៃនីតិវិធីនៅក្នុងសប្តាហ៍នេះ តុលាការបានស្តាប់សវនាការលើការបង្ហាញឯកសារដែលនៅសេសសល់ទាំងឡាយក្នុងសំណុំរឿង ០០២/០១ ដើម្បីជជែកដេញដោលចាប់តាំងពីខែមេសា ឆ្នាំ២០១១ ពីតារាងភស្តុតាងឯកសារ។ អនុស្សរណៈចុះនៅថ្ងៃទី១៧ ខែមករា បានថ្លែងថា តុលាការនឹងស្តាប់សវនាការលើឯកសារ ដែលយោងទៅតាមកថាខណ្ឌនៃដីកាដំណោះស្រាយ ទាក់ទងនឹងការជម្លៀសប្រជាពលរដ្ឋ និងទីតាំងសម្លាប់នៅទួលពោធិជ្រៃ[6] និងឯកសារទាំងចំនួន៩៤ ស្តីពីបញ្ហាការជម្លៀសប្រជាជន និងទីតាំងសម្លាប់នៅទួលពោធិជ្រៃ ដែលការិយាល័យសហព្រះរាជអាជ្ញាបានដាក់ចំពោះមុខអង្គជំនុំជម្រះ មុនពេលថ្ងៃកំណត់ចុងក្រោយនៃការដាក់សំណើ។[7] សហព្រះរាជអាជ្ញា បានបង្ហាញឯកសារចំនួន៤៨ ដែលនៅតែតម្រូវឲ្យមានការជជែកដេញដោល ហើយវាមិនស្ថិតនៅក្នុងលក្ខខណ្ឌលើកលែងរបស់អង្គជំនុំជម្រះសម្រាប់សេចក្តីថ្លែងការណ៍របស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដែលនឹងត្រូវយកមកប្រើប្រាស់នៅសវនាការនាពេលខាងមុខ។[8] នៅក្នុងដំណាក់កាលដំបូងនៃសវនាការ អង្គជំនុំជម្រះបានផ្តល់ថេរវេលាដល់មេធាវីការពារក្តីលោក អៀង សារី ដើម្បីបង្ហាញការទំទាស់របស់គាត់ទៅនឹងឯកសារចំនួន៥៤ ចាប់តាំងពីខែមេសា ឆ្នាំ២០១១ នៃតារាងភស្តុតាងឯកសារទៅតាមផ្នែក ដែលបានកំណត់ក្នុងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះចុះនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២។[9]

#### *ក.១. ការជជែកដេញដោលលើការទទួលស្គាល់ឯកសារក្នុងឧបសម្ព័ន្ធ១*

លោកព្រះរាជអាជ្ញា **វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល** (Mr. *Vincent de Wilde d'Estmael*) បានចាប់ផ្តើមនីតិវិធីនៅសប្តាហ៍នេះ ជាមួយនឹងការបង្ហាញឯកសារឧបសម្ព័ន្ធ១[10] ដែលជាតារាងមួយមានឯកសារចំនួន៤៨ បានមកពីគ្រប់ភាគីទាំងអស់ ដែលសហព្រះរាជអាជ្ញាបានរកឃើញនៅក្នុងសំណើ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ ថា ជាឯកសារតម្រូវឲ្យមានការជជែកដេញដោល។[11]

### *ក.១.ក. ការធ្វើបទបង្ហាញឯកសារឧបសម្ព័ន្ធ១ និងការជំទាស់ដោយសហព្រះរាជអាជ្ញា*

ព្រះរាជអាជ្ញា **វ៉ាយជ៍ ដេស្មាឯល** បានចាប់ផ្តើមដោយធ្វើបទបង្ហាញឧបសម្ព័ន្ធ១ ជាឯកសារដែលនៅសេសសល់ ហើយនិងស្នើឡើងដោយគ្រប់ភាគី ដែលមិនទាន់បានជជែកដេញដោលលើភាពទទួលស្គាល់បាននៃឯកសារទាំងនេះ។ ក្រៅពីឯកសារចំនួន៤៨ ដែលមាននៅក្នុងឧបសម្ព័ន្ធ១ អង្គជំនុំជម្រះ ឬភាគី អាចធ្វើការបង្ហាញឯកសារចំនួន៤៦នៅចន្លោះខែកក្កដា ឆ្នាំ២០១១ និងខែវិច្ឆិកា ឆ្នាំ២០១២[12] ដែលក្នុងចំណោមឯកសារទាំងនេះមានចំនួន៦ ជាឯកសាររបស់សហព្រះរាជអាជ្ញា មានចំនួន៣ ជារបស់ដើមបណ្តឹងរដ្ឋប្បវេណី ចំនួន៣៣ ជារបស់ក្រុមមេធាវីការពារក្តីលោក **ខៀវ សំផន** និងចំនួន១១ ជារបស់ក្រុមមេធាវីការពារក្តីលោក **នួន ជា**។

បន្ទាប់មក ព្រះរាជអាជ្ញា **វ៉ាយជ៍ ដេស្មាឯល** បានធ្វើបទបង្ហាញពីការជំទាស់របស់សហព្រះរាជអាជ្ញាចំពោះឯកសារចំនួន៤ របស់ជនជាប់ចោទ **ខៀវ សំផន** និងចំនួន៤ទៀតរបស់លោក **នួន ជា**។ គាត់បានអានលេខសម្គាល់នៃឯកសារយោងទាំង៤នេះ ដែលមានបុគ្គលផ្សេងៗគ្នាបានផ្ញើទៅលោក **ខៀវ សំផន** ដើម្បីបង្ហាញពីតួនាទីរបស់គាត់ក្នុងសម័យខ្មែរក្រហម ដើម្បីសុំឲ្យមានការអនុគ្រោះ។[13] ព្រះរាជអាជ្ញា បានបដិសេធទៅនឹងសក្ខីកម្មទាំងអស់នេះនៅក្រោយដំណាក់កាលស៊ើបអង្កេត ដែលបានធ្វើឡើងដោយឯកតោភាគី "ហើយមិនមានការអនុញ្ញាតពីអង្គជំនុំជម្រះ។"[14] លោក **វ៉ាយជ៍ ដេស្មាឯល** បានបញ្ចប់ការដាក់បង្ហាញឯកសាររបស់លោក ដោយការជំទាស់លើឯកសារចំនួន៤របស់មេធាវីការពារក្តីលោក **នួន ជា**។[15] ការបដិសេធនេះ បានសម្អាងលើភាពមិនជាប់ពាក់ព័ន្ធនៃឯកសារ ដូចជាបញ្ហាទាក់ទងនឹងនាយករដ្ឋមន្ត្រីបច្ចុប្បន្ន គឺលោក **ហ៊ុន សែន**។

### *ក.១.ខ. ការឆ្លើយតបរបស់ក្រុមការពារក្តីទៅនឹងបទបង្ហាញឧបសម្ព័ន្ធ១ និងការជំទាស់តវ៉ាចំពោះសហព្រះរាជអាជ្ញាដោយក្រុមមេធាវីការពារក្តី*

មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ **នួន ជា** គឺលោក **វិចទ័រ កូប៉េ** (*Mr. Victor Koppe*) បានបដិសេធមិនផ្តល់មតិយោបល់លើការជំទាស់តវ៉ារបស់សហព្រះរាជអាជ្ញាទេ។ គាត់មិនមានការជំទាស់អ្វីបន្ថែមទៀតទេ នៅលើឯកសារដែលនៅសេសសល់ក្នុងឧបសម្ព័ន្ធ១។ មេធាវីអន្តរការពារក្តីជាតិឲ្យជនជាប់ចោទ **ខៀវ សំផន** គឺកញ្ញា **អាន់តា ហ្គីសេ** (*Ms. Anta Guissé*) បានលើកឡើងនូវការជំទាស់អំពីសំបុត្រចំនួន៤របស់ព្រះរាជអាជ្ញា **វ៉ាយជ៍ ដេស្មាឯល** ដោយលើកហេតុផលថា ម្ចាស់សំបុត្រទាំង៤នេះ ត្រូវបានស្នើរួចជាស្រេចដោយតុលាការ ឲ្យមកធ្វើជាសាក្សី។[16] កញ្ញា **ហ្គីសេ** បានបញ្ជាក់ថា សាក្សីដែលអាចត្រូវបានកោះហៅទាំងនេះ អាចផ្តល់ភស្តុតាងដោះបន្ទុក ដោយពួកគេស្គាល់កូនក្តីរបស់ខ្លួន ហើយអាចបង្ហាញបរិបទល្អៗពីការរស់នៅក្នុងជីវិត និងការងាររបស់កូនក្តីរបស់ខ្លួន។

មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ **អៀង សារី** គឺលោក **ម៉ៃឃើល ខាណាវ៉ាស** (*Mr. Michael Karnavas*) បានជំទាស់ម្តងហើយម្តងទៀតលើឯកសារទាំងនេះ ដូចដែលគាត់បានធ្វើកាលពីសវនាការលើឯក

សារមុនៗ។[17] គាត់បានសួរសាជាថ្មីលើការវាយតម្លៃភស្តុតាងនៃរបាយការណ៍ស៊ើបសួររបស់សហព្រះរាជអាជ្ញាស៊ើបអង្កេត ដោយគាត់គ្រាន់តែចាត់ទុកវាថា "ជាសេចក្តីសង្ខេបមួយពីសេចក្តីសង្ខេបតែប៉ុណ្ណោះ។[18]" គាត់បានសួរនាំពីសារធាតុដើមនៃខ្សែវីដេអូដែលមាននៅក្នុងសំណុំរឿង និងប្រភពដើមនៃខ្សែវីដេអូខ្លីទាំងអស់ ដែលត្រូវបានគេកាត់ត។[19] ទាក់ទងទៅនឹងរបាយការណ៍ពីរដ្ឋាភិបាលបរទេស ឬ អង្គការអន្តរជាតិ អត្ថបទសិក្សាស្រាវជ្រាវ ឬ អត្ថបទកាសែតផ្សេងៗ ដែលក្រុមការពារក្តីបានបញ្ជាក់ថា អ្នកនិពន្ធត្រូវតែមកបញ្ជាក់ពីភាពពិតនៃព័ត៌មាននៅក្នុងឯកសារទាំងនោះនៅចំពោះមុខអង្គជំនុំជម្រះ។[20] លោក **ខាណាវ៉ាស** ក៏បានជំទាស់តវ៉ាទៅនឹងការប្រើប្រាស់ចម្លើយសារភាពបានដោយទារុណកម្មមកធ្វើជាភស្តុតាង ដោយលើកហេតុផលថា ព័ត៌មានលម្អិតពាក់ព័ន្ធទាំងនេះគឺប្រៀបដូចជា "ផ្លែឈើល្អ បានមកពីដើមឈើដែលមានជាតិពុល។"[21]

### *ក.១.គ. ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងមតិរបស់ក្រុមការពារក្តី*

ជាកិច្ចឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមការពារក្តី លោក **វ៉ាយដ៍ ដេស្មាឯល** បានគូសបញ្ជាក់ថា អង្គជំនុំជម្រះ បានសម្រេចចិត្តរួចជាស្រេចលើសេចក្តីជំទាស់របស់លោក **ខាណាវ៉ាស** នៅក្នុងសេចក្តីសម្រេច៣ផ្សេងគ្នា រួមមាន ការទទួលយកបានចំពោះការប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម។[22] គាត់ក៏បានឆ្លើយតបវិញថា អង្គជំនុំជម្រះបានកំណត់រួចជាស្រេចថា ឯកសារទាំងនេះទោះបីជា សៀវភៅ ខ្សែវីដេអូ ព័ត៌មាន ឬ អត្ថបទព័ត៌មានក៏ដោយ វាមិនចាំបាច់តម្រូវឲ្យក្លាយជាភស្តុតាងភ្លាមៗទេក្នុងអំឡុងពេលសួរដេញដោលសាក្សី ហើយអង្គជំនុំជម្រះនឹងសម្រេចលើតម្លៃភស្តុតាងរបស់ឯកសារទាំងនេះតាមការគួរ។[23] ជាពិសេសទាក់ទងនឹងខ្សែវីដេអូសម្ភាសន៍របស់ **តិត សម្បត្តិ** ជាមួយលោក **ខៀវ សំផន** លោក **វ៉ាយដ៍ ដេស្មាឯល** បានយល់ឃើញថា សភាពការណ៍ជុំវិញកិច្ចសម្ភាសន៍មានជាប់ពាក់ព័ន្ធនឹងបញ្ហាតម្លៃនៃភស្តុតាង មិនមែនការទទួលស្គាល់ឯកសារទេ។ សូមត្រឡប់ទៅពិនិត្យមើលបញ្ហាសំបុត្រទាំង៤ ទៅកាន់លោក **ខៀវ សំផន** វិញ លោក **វ៉ាយដ៍ ដេស្មាឯល** បានយល់ស្របថា ម្ចាស់សំបុត្រទាំងអស់នេះ គឺនៅក្នុងបញ្ជីសាក្សី ប៉ុន្តែគាត់បានស្នើឲ្យអង្គជំនុំជម្រះ បង្ហាញពីស្ថានភាពបែបណាទៅ ទើបមេធាវីអាចធ្វើទំនាក់ទំនងនឹងសាក្សីទាំងនេះបាន។

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ គឺលោក **ពេជ អង្គ** បានគាំទ្រនឹងការឆ្លើយតបរបស់លោក **វ៉ាយដ៍ ដេស្មាឯល** លើខ្សែវីដេអូកិច្ចសម្ភាសន៍ ដោយបានបន្ថែមថា **នួន ជា** និង **ខៀវ សំផន** បានមានសេរីភាពពេញលេញក្នុងការនិយាយនាពេលនោះ។ បន្ទាប់មក សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ អ្នកស្រី **អេលីហ្សាបេត ស៊ីម៉ុនណូ ហ្វត** (*Ms. Elisabeth Simonneau-Fort*) បានធ្វើសេចក្តីថ្លែងការណ៍ ហើយបញ្ជាក់ម្តងទៀតថា អង្គជំនុំជម្រះ បានដោះស្រាយលើសេចក្តីជំទាស់របស់ក្រុមការពារក្តីរួចជាស្រេចនៅក្នុងសេចក្តីសម្រេចមុនៗ។ អ្នកស្រីបានបន្តទៀតថា អង្គជំនុំជម្រះគួរតែបដិសេធនឹងសេចក្តីជំទាស់ទូទៅ និងសេចក្តីជំទាស់ធ្វើឡើយដោយសំណើលាយលក្ខណ៍អក្សរ ដែលពាក់ព័ន្ធនឹងឯកសារទាំងឡាយណាដែលបានពិភាក្សារួចហើយ។ លោក **ខាណាវ៉ាស**

និងកញ្ញា **ហ្គីសសេ** ទាំងពីរនាក់ បានឆ្លើយតបទៅការអះអាងទាំងនេះ ហើយបានពន្យល់ការយល់ឃើញរបស់ពួកគេ ចំពោះគោលបំណងនៃសវនាការលើឯកសារ (សូមមើល ផ្នែកទី៣. ១.)។

### *ក.២. ការដាក់សំណើឯកសារលើការជម្លៀសប្រជាជនដោយបង្ខំ និងនៅទួលពោធិជ្រៃ*

បន្ទាប់មក ព្រះរាជអាជ្ញា **វ៉ាយង៍ ដេស្មាឯល** បានបន្តដាក់បង្ហាញឧបសម្ព័ន្ធ២(ក-គ)[24] ដែលរួមបញ្ចូលឯកសារទាំងអស់ចំនួន៩៤ ទាក់ទងនឹងដំណាក់កាលទី១ និងទី២នៃជម្លៀសប្រជាជន និងទួលពោធិជ្រៃ ដែលសហព្រះរាជអាជ្ញាមានបំណងចង់ដាក់បញ្ចូលទៅក្នុងសំណុំរឿង។[25] ក្នុងខណៈដែលភាគីទាំងអស់ បានទទួលបញ្ជីឯកសាររួចជាស្រេច លោក **វ៉ាយង៍ ដេស្មាឯល** បានស្នើថា គាត់នឹងមិនអានឯកសារទាំងនេះមកក្រៅទេ។ អង្គជំនុំជម្រះបានទទួលយកសំណើនេះ ហើយកិច្ចដំណើរការនីតិវិធីនេះ បានដំណើរការភ្លាមដោយឆ្លើយតបទៅនឹងភាគីផ្សេងៗទៀតពាក់ព័ន្ធនឹងឯកសារទាំងនេះ។

#### *ក.២.ក. សេចក្តីជំទាស់របស់ក្រុមការពារក្តី*

ក្រុមការពារក្តីឲ្យលោក **នួន ជា** បានបដិសេធមិនផ្តល់យោបល់ជាថ្មីម្តងទៀត ដោយសារតែ ពួកគេមិនទាន់បានពិភាក្សាជាមួយកូនក្តីរបស់គាត់។ លោក **ខាណាវ៉ាស** បានប្រកាសថា គាត់នឹងមិនអានចេញមកក្រៅពីសំណើ៦៥ទំព័រជាលាយលក្ខណ៍អក្សរទេ ដែលក្រុមរបស់គាត់បានរៀបចំជាស្រេច ប៉ុន្តែគាត់នឹងផ្តល់ការយល់ឃើញដោយផ្ទាល់មាត់ទាក់ទងនឹងផ្នែកនីមួយៗនៃឯកសារ ដែលគាត់មិនបានលើកឡើងកន្លងមកទាក់ទងនឹងឧបសម្ព័ន្ធ១។[26] បន្ទាប់មក គាត់បានបន្តផ្តល់យោបល់លើការប្រើប្រាស់រូបភាព និងនិយាយម្តងទៀតថា ការទទួលយករូបថតទាំងនេះ គឺអាស្រ័យលើសក្ខីកម្មផ្ទាល់មាត់ដែលអាចបង្ហាញពីបរិបទ និងអត្ថន័យនៃរូបថតទាំងនេះបាន។[27] លោក **ខាណាវ៉ាស** ក៏បានបដិសេធទៅនឹងឯកសារដែលបានមកពីកំណត់ហេតុស្រុកត្រាំកក់។[28] គាត់បានរំឭកតុលាការថា នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា លោក **យុ ឆាង** មិនអាចបញ្ជាក់ពីដំណើររក្សាភស្តុតាង ហើយថា លោក **បេន ឃីនិន** (*Mr. Ben Kiernan*) បានពន្យល់ទៅកាន់សហចៅក្រមស៊ើបអង្កេតថា គាត់ធ្លាប់បានកាន់ឯកសារដើមបានម្តង ហើយបានថតចម្លងឯកសារទាំងនេះ ប៉ុន្តែក្រោយមក ឯកសារដើមត្រូវបានបាត់ទៅ។ ដូច្នេះ គាត់បានពន្យល់ថា "មិនមានការបង្ហាញឯករាជ្យណាមួយពីភាពគួរឲ្យទុកចិត្តបានពីយថាភាពរបស់ឯកសារទាំងនេះបានទេ។"[29] កញ្ញា **ហ្គីសសេ** ក៏បានលើកបញ្ហានៃការទទួលយកបាននៃកំណត់ហេតុស្រុកត្រាំកក់ ជាពិសេស កំណត់ហេតុដែលមិនមានអត្តសញ្ញាណអ្នកនិពន្ធ[30] ដោយអះអាងថា ឯកសារទាំងឡាយណាដែលមិនមានអ្នកនិពន្ធ គួរតែទទួលបានតម្លៃភស្តុតាងតិចតួច។

#### *ក.២.ខ. ការឆ្លើយតបរបស់ព្រះរាជអាជ្ញា*

លោក **វ៉ាយង៍ ដេស្មាឯល** បានយកចិត្តទុកដាក់ឆ្លើយតបរបស់គាត់ទាំងស្រុង មកលើផ្នែកនៃឯកសារដែលមិនទាន់បានពិភាក្សានៅក្នុងកិច្ចពិភាក្សាមុនៗ មានដូចជា រូបថត និងកំណត់ហេតុស្រុកត្រាំកក់។ ជាថ្មីម្តងទៀត

គាត់បានគូសបញ្ជាក់ថា ការទទួលយកឯកសារ រូបថត មិនចាំបាច់តម្រូវឲ្យរូបថត ឯកសារទាំងនេះបានបង្ហាញនៅក្នុងតុលាការទេ។ គាត់បាននិយាយពីការការពារដាក់បញ្ចូលរូបថតទាំងនេះផងដែរ។ ឧទាហរណ៍ គាត់បានពន្យល់ថា មានរូបថតពីរបានមកពីឧបសម្ព័ន្ធ២(ក) ត្រូវបានយកចេញនៅពេលជម្លៀសប្រជាជនចេញពីភ្នំពេញប្រហែលជានៅជុំវិញថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយ ឯកសារទាំងនេះមានភាពពាក់ព័ន្ធ ពីព្រោះវាជាឯកសារក្នុងសម័យកម្ពុជាប្រជាធិបតេយ្យតែម្តង។[31]

ទាក់ទងនឹងកំណត់ហេតុស្រុកត្រាំកក់ លោក **វ៉ាយជ៍ ដេស្មាឯល** បានគូសបញ្ជាក់ថា នៅខែមីនា ឆ្នាំ២០១២ មានឯកសារមួយចំនួនបានមកពីបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានពិភាក្សាដេញដោលស្រដៀងគ្នានេះដែរ ចំពោះភាពពាក់ព័ន្ធ និងភាពគួរឲ្យជឿទុកចិត្តបាននៃឯកសារ។[32] លោក **វ៉ាយជ៍ ដេស្មាឯល** បានលើកឡើងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ ដែលថា បានទទួលយកឯកសារចំនួន៥៧រួចជាស្រេច[33] ហើយកំណត់ហេតុស្រុកត្រាំកក់ចំនួន៤៩ គឺស្ថិតនៅក្នុងសំណុំឯកសារតែមួយ។ យ៉ាងណាក៏ដោយ លោកព្រះរាជអាជ្ញា បានបញ្ជាក់ម្តងហើយម្តងទៀតពីភាពពាក់ព័ន្ធនៃឯកសារទាំងនេះ ដោយពន្យល់ថា ឯកសារទាំងនេះបានបង្ហាញពីប្រព័ន្ធទំនាក់ទំនង និងរចនាសម្ព័ន្ធរដ្ឋបាលក្នុងស្រុក១០៥។ គាត់បានបន្តអះអាងថា កំណត់ហេតុទាំងនេះ បានបង្ហាញបីការអនុវត្តន៍របស់ស្រុក នូវគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ជាពិសេសការអប់រំកែប្រែឡើងវិញនូវសារធាតុអាក្រក់ ការលុបបំបាត់ចោលខ្មាំងសត្រូវ និងវិធានការជាក់លាក់ប្រឆាំងនឹងអតីតមន្រ្តីសាធារណរដ្ឋខ្មែរ។[34] នៅក្នុងការតវ៉ាទាក់ទងនឹងការបាត់ឯកសារដើមរបស់លោក **ខាណាវ៉ាស** លោក **វ៉ាយជ៍ ដេស្មាឯល** បានរំឭកជាថ្មីម្តងទៀតថា លោក **យុក ឆាង** បានធ្វើសក្ខីកម្មលើបញ្ហាអស់នេះរួចជាស្រេច។ ទោះបីជា ព្រះរាជអាជ្ញាបានដឹងថា ឯកសារទាំងនេះត្រូវបានសរសេរដោយដៃក៏ដោយ គាត់បានសង្កេតថា ភាសានៅក្នុងឯកសារទាំងនេះ វាស្របទៅនឹងកំណត់ហេតុផ្សេងៗទៀតនៅសម័យកម្ពុជាប្រជាធិបតេយ្យហើយដែលថា បទសម្ភាសន៍សាក្សីជាមួយសហចៅក្រមស៊ើបអង្កេតជាច្រើន បានបញ្ជាក់ឲ្យឃើញពីយថាភាពរបស់ឯកសារទាំងអស់នេះ។ ជាចុងក្រោយ គាត់បានច្រានចោលការជំទាស់របស់កញ្ញា **ហ្គីសេ** លើឯកសារខ្លះៗដែលមិនមានអ្នកនិពន្ធត្រឹមត្រូវ ដោយសារមិនមានហេតុផលគ្រប់គ្រាន់ដើម្បីបដិសេធមិនទទួលយកឯកសារទាំងនេះ។

### *ក.៣. សេចក្តីជំទាស់របស់ក្រុមការពារក្តី អៀង សារី ទៅនឹងឯកសារចំនួន៥៤*

នៅក្នុងផ្នែកចុងក្រោយនៃដំណាក់កាលដំបូងនៃសវនាការលើឯកសារ អង្គជំនុំជម្រះ បានផ្តល់មាតិកាឲ្យក្រុមការពារក្តីលោក **អៀង សារី** ដើម្បីធ្វើបទបង្ហាញសំណើលើឯកសារចំនួន៥៤ ដែលត្រូវបានពិភាក្សារួចហើយកាលពីកិច្ចដំណើរការនីតិវិធីមុនៗ ដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា ដំណាក់កាលទី១ និងទី២នៃការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ។[35] លោក **វ៉ាយជ៍ ដេស្មាឯល** បាននិយាយកាត់ មុនពេលលោក **ខាណាវ៉ាស** ចាប់ផ្តើមបង្ហាញលើឯកសារ ដោយលោកលើកឡើងថា ឯកសារចំនួន១៤ គឺត្រូវបានពិភាក្សា ហើយមាននៅក្នុងសេចក្តី

សម្រេចរបស់អង្គជំនុំជម្រះរួចជាស្រេច រួមទាំងឯកសារចំនួន១២ ដែលត្រូវបានបង្ហាញក្នុងអំឡុងពេលសវនាកាលពីម្សិលមិញ ហើយឯកសារខ្លះទៀតត្រូវបានពិភាក្សានៅឆ្នាំ២០១២។ ដូច្នេះ លោក **វ៉ាយដ៍ ដេស្មាឯល** បានស្នើឲ្យតុលាការពន្យល់ពីហេតុផល ដែលអង្គជំនុំជម្រះបានកំណត់បញ្ជីភស្តុតាងនៃឯកសារចំនួន៥៤ មកត្រឹមតែ៣០ទៅវិញ។

លោក **ខាណាវ៉ាស** បានឆ្លើយតបវិញដោយរម្លឹកថា ការជំទាស់ជាក់លាក់ទៅនឹងឯកសារទាំង៥៤នេះបានធ្វើឡើងតាមសំណើជាលាយលក្ខណ៍អក្សរ។ បន្ទាប់មក គាត់បានបន្តលើកឡើងពីសេចក្តីជំទាស់ទូទៅរបស់គាត់លើប្រធានបទ និងប្រភេទឯកសារ។ លោក **ខាណាវ៉ាស** បានទទួលស្គាល់ថា គាត់ពិតជាបានជំទាស់ដដែលៗពាក់ព័ន្ធនឹងការបទបង្ហាញរបស់ព្រះរាជអាជ្ញាលើឧបសម្ព័ន្ធ១ និង២(ក-គ) (សូមមើលផ្នែកទី២ ក.១.ខ. និងផ្នែកទី២ ក.២.ក.) ប៉ុន្តែ គាត់បានអះអាងផងដែរថា ឯកសារខ្លះមិនគួរទទួលយកទេ ដោយផ្អែកតាមស្តង់ដានៃវិធានផ្ទៃក្នុង ៨៧(៣)។[36] លោក **ខាណាវ៉ាស** បាននិយាយពីប្រភេទឯកសារខ្លះ ដែលមាននៅក្នុងបញ្ជីឯកសារទាំង៥៤របស់គាត់ ដូចជាសារទូរលេខ សំបុត្រ ឯកសារមកពីប្រទេសបារាំង សហរដ្ឋអាមេរិក អង្គការថវិកាសង្គ្រោះបន្ទាន់សម្រាប់កុមារអន្តរជាតិរបស់អង្គការសហប្រជាជាតិ (**UNICEF**) និងអង្គការសុខភាពពិភពលោក (**WHO**) អត្ថបទកាសែត[37] កំណត់ហេតុកិច្ចប្រជុំ និងអត្ថបទបោះពុម្ពផ្សព្វផ្សាយរបស់កម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាវីដេអូមួយដែលមានចំណងជើងថា "តើមានអ្វីកើតឡើងមកលើប្រទេសកម្ពុជា" ដោយលោក **រូនី យ៉ីមស៊ុត** (*Mr. Ronnie Yimsut*)។ គាត់បានថ្លែងផងដែរថា ក្រុមការពារក្តីឲ្យលោក **អៀង សារី** បានជំទាស់នឹងឯកសារណា ដែលបានធ្វើឡើងមុនយុត្តាធិការដែលតុលាការនេះមាន។ លោកមេធាវីបានជំទាស់ជាក់លាក់ម្តងទៀតទៅកាន់ឯកសារដែលផលិតដោយ លោក **ស្ទេហ្វិន ហេដ័រ** (*Mr. Stephen Heder*)។[38]

ដូច្នេះ មេធាវីការពារក្តី បានបញ្ចប់ការធ្វើបទបង្ហាញរបស់គាត់ ជាជាងការឆ្លើយតបទៅនឹងសេចក្តីជំទាស់ពីដើមរបស់សហព្រះរាជអាជ្ញា **វ៉ាយដ៍ ដេស្មាឯល** ដែលបានលើកឡើងថា ឯកសារចំនួន២៤បានពិភាក្សាដេញដោលកន្លងមកហើយ ប៉ុន្តែការជំទាស់របស់លោក មិនបានទទួលការយល់ព្រមពីលោកប្រធានចៅក្រមទេ។ ចំពោះឯកសារនៅសេសសល់ទាំងអស់ លោក **វ៉ាយដ៍ ដេស្មាឯល** បានក្រើនរម្លឹកតុលាការថា សេចក្តីថ្លែងការរបស់សាក្សីខ្លះ បានរាប់បញ្ចូលសាក្សីក្នុងបញ្ជីក្រុមមេធាវីការពារក្តី នឹងត្រូវលើកយកមកពិភាក្សានៅក្នុងសវនាការនាពេលក្រោយទៀត ដែលបានត្រូវបានសម្រេចរួចហើយដោយអង្គជំនុំជម្រះនៅក្នុងសេចក្តីសម្រេចមុនៗ។ បន្ទាប់មក លោក **ខាណាវ៉ាស** បានឆ្លើយតបទៅនឹងព្រះរាជអាជ្ញា ដោយបានទទួលស្គាល់ថា ប្រហែលជាមានឯកសារជាន់គ្នានៅក្នុងបញ្ជីឯកសារទាំង៥៤ ដោយសារតែការរៀបចំប្រញាប់ប្រញាល់ពេក ប៉ុន្តែគាត់បានបញ្ជាក់ម្តងទៀតថា ក្រុមរបស់គាត់នឹងបន្តដាក់បង្ហាញសេចក្តីជំទាស់តាមប្រធានបទនីមួយៗ។

## ខ. ដំណាក់កាលទី២នៃសវនាការលើឯកសារ

អនុស្សរណៈរបស់អង្គជំនុំជម្រះតុលាការដំបូងចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៣ មានបំណងដាក់ដំណាក់កាលទី២នៃសវនាការ លើឯកសារឲ្យភាគីធ្វើបទបង្ហាញដែលពួកគេគិតថាមានភាពពាក់ព័ន្ធខ្លាំងក្នុងការបញ្ជាក់ការពិតក្នុងសំណុំរឿង ០០២/០១។ អនុស្សរណៈនេះ បានបង្ហាញពីផ្នែកអង្គហេតុដែលនៅសេសសល់មានដូចជាដំណាក់កាលទី១ និងទី២នៃការជម្លៀសប្រជាជន ទួលពោធិ៍ជ្រៃ រចនាសម្ព័ន្ធយោធា សហឧក្រិដ្ឋរួម និងតួនាទីរបស់ជនជាប់ចោទ។[39] ដំបូងឡើយ សហព្រះរាជអាជ្ញា បានបង្ហាញឯកសារទាក់ទងនឹងផ្នែកទាំងបួននៃរឿងក្តីនេះ និងដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើបទបង្ហាញឯកសាររបស់ខ្លួន មុនពេលក្រុមការពារក្តីទទួលបានពេលវេលាដាក់សំណើឆ្លើយតបផ្ទាល់មាត់។ យ៉ាងណាមិញ ព្រះរាជអាជ្ញាអន្តរជាតិ លោក **ឃីត រេយ៍ន័រ** (*Mr. Keith Raynor*) បានបញ្ជាក់ថា សហព្រះរាជអាជ្ញាមិនទាន់បានរៀបចំធ្វើបទបង្ហាញដាក់ឯកសារលើគោលនយោបាយ សហឧក្រិដ្ឋរួម ឬ តួនាទីរបស់ជនជាប់ចោទឡើយ។

### *ខ.១. ការធ្វើបទបង្ហាញឯកសារលើរចនាសម្ព័ន្ធយោធារបស់សហព្រះរាជអាជ្ញា*

ជាដំបូង ព្រះរាជអាជ្ញា **សេង ប៊ុនឃាង** បានដាក់បង្ហាញឯកសារលើរចនាសម្ព័ន្ធយោធា និងការអភិវឌ្ឍន៍វិស័យយោធាដោយថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ គាត់បានចាប់ផ្តើមជាមួយនឹងទង់បដិវត្តន៍ ចុះនៅខែសីហា ឆ្នាំ១៩៧៥ ដែលត្រូវបានបោះពុម្ពផ្សាយ ចាប់ពីព្រឹត្តិការណ៍នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៥ ពីសេចក្តីចាំបាច់ក្នុងការបង្កើតកងទ័ពបដិវត្តន៍កម្ពុជាដើម្បីការពារ និងកងសាងប្រទេសជាតិ ហើយបានអះអាងថា "បក្សត្រូវដឹកនាំប្រជាជនប្រើហិង្សា ប្រើអំពើសងឈាមវិញ ជានយោបាយក្តី ឬ ជាយោធាក្តី។"[40] ការធ្វើបទបង្ហាញបានបន្តធ្វើជាមួយនឹងឯកសារពាក់ព័ន្ធនឹងប្រព័ន្ធរាយការណ៍នៅក្នុងកងទ័ពបដិវត្តន៍កម្ពុជា និងអាជ្ញាធរនៃគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា។[41] បន្ទាប់មក លោក **សេង ប៊ុនឃាង** បានដាក់ឯកសារនៅចំពោះមុខតុលាការ អំពីរចនាសម្ព័ន្ធការងារយោធាចាប់ពីថ្នាក់មូលដ្ឋានដល់ថ្នាក់មជ្ឈិម។[42] ជាចុងក្រោយនៃការដាក់បង្ហាញឯកសាររបស់ព្រះរាជអាជ្ញាជាតិ បានផ្តោតលើតួនាទីរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងរចនាសម្ព័ន្ធយោធា។[43] គាត់បានប្រើប្រាស់បទសម្ភាសន៍ដាច់ដោយឡែកពីគ្នា ជាមួយនឹងសមាជិកគណៈអចិន្ត្រៃយ៍នៅកំពង់សោម ដែលបានភៀសខ្លួនទៅប្រទេសថៃ និងបទសម្ភាសន៍ជាមួយ **អៀង សារី** ដើម្បីកំណត់ពីអំណាចរបស់មេដឹកនាំកំពូលបំផុតទាក់ទងនឹងបញ្ហាសុវត្ថិភាព។[44] ឧទាហរណ៍៖ ព្រះរាជអាជ្ញាបានដាក់បង្ហាញសេចក្តីថ្លែងកាជាផ្លូវការមួយនៅឆ្នាំ១៩៩៦ ចេញពីក្រុមរបស់ **អៀង សារី** ដែលហៅថា "ជើងកាងទាំងបួន" មានដូចជា **ប៉ុល ពត**, **នួន ជា**, **សុន សេន**, **យុន យ៉ាត** "ជាអ្នកសម្រេចរាល់ការសម្លាប់ និងការសម្លាប់រង្គាល។"[45]

ព្រះរាជអាជ្ញា **ខេល លីសាក់** បានធ្វើបទបង្ហាញបន្តលើឯកសារដែលនៅសេសសល់ ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា ដោយដំបូងឡើយបានលើកឡើងឯកសារពីសេនាធិការដ្ឋាន និងកងពលកណ្តាលនៃកងទ័ពបដិវត្តន៍កម្ពុជាដើម្បីបង្ហាញពីខ្សែចង្វាក់លំដាប់សក្តិនៃការបញ្ជាក្នុងកម្ពុជាប្រជាធិបតេយ្យ។ ព្រះរាជអាជ្ញាអន្តរជាតិ

បានដាក់បង្ហាញឯកសារតាមលំដាប់លំដោយនៃពេលវេលាដើម្បីបង្ហាញថា ខ្សែចង្វាក់នៃការបញ្ជានៅតែមានដដែលនៅក្នុងរបបនេះ។ លោក **លីសាក់** បានចាប់ផ្តើមជាមួយនឹងឯកសារចាប់ពីប៉ុន្មានខែចុងក្រោយបន្ទាប់ពីការដួលរលំភ្នំពេញ ដែលបក្សបានបញ្ជាឲ្យកម្ចាត់ចោលជនក្បត់ទាំង១៧របស់របប **លន់ នល់**។[46] បន្ទាប់មក លោកសហព្រះរាជអាជ្ញា បានដាក់បង្ហាញឯកសារនៅពាក់កណ្តាលឆ្នាំ ១៩៧៦ ដែលស្តែងឲ្យឃើញពីទំនាក់ទំនងនៃខ្សែសង្វាក់នៃការបញ្ជា និងពីរបៀបនៃការសម្រេចចិត្ត និងនយោបាយរបស់បក្ស ដែលត្រូវបានអនុវត្តនៅថ្នាក់កងពល។[47] នៅថ្ងៃទី២នៃសវនាការ លោក **លីសាក់** បានបន្តដាក់បង្ហាញឯកសារសំខាន់ៗ ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៦ ដោយលាតត្រដាងពីចំណុចដែលឯកសារទាំងនេះ បានបង្ហាញពីរបៀបនៃការផ្សព្វផ្សាយគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ទៅកាន់គ្រប់ស្ថាប័នទាំងអស់។[48] គាត់បានប្រើប្រាស់ឯកសារមួយ "សេចក្តីសម្រេចចិត្តរបស់សន្និបាត គណៈកម្មាធិការបក្សគ្រប់កងពល" ចាប់ពីខែកក្កដា ឆ្នាំ១៩៧៦ ដែលបានធានាឲ្យមាន ការប្រុងប្រយ័ត្នខ្ពស់របស់កងទ័ពបដិវត្តន៍កម្ពុជាពីខ្មាំងបៀតបៀនផ្ទៃក្នុង សម្រិតសម្រាំងជួរកងទ័ព និងកសាងបក្សតាមការផ្សព្វផ្សាយចែកចាយលក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា។[49]

បន្ទាប់មក លោក **លីសាក់** បានចំណាយពេលមួយផ្នែកធំរៀបរាប់លម្អិតពីឯកសារ ពាក់ព័ន្ធនឹងស្ថានការណ៍ខ្មាំងស៊ីរូងផ្ទៃក្នុង និងប្រព័ន្ធទំនាក់ទំនងរវាងលំដាប់ថ្នាក់ផ្សេងៗ លើបញ្ហាចាប់ខ្លួនខ្មាំង និងការគំរាមកំហែងផ្ទៃក្នុង។[50] លោកព្រះរាជអាជ្ញា បានប្រើប្រាស់ការពិភាក្សាផ្ទៃក្នុងរបស់ **ចាន់ ចក្រី** អតីតមេកងពល១៧០ អ្នកដែលបានប៉ុនប៉ងកសាងបណ្តាញមួយ ដើម្បីធ្វើឲ្យអន្តរាយដល់របបកម្ពុជាប្រជាធិបតេយ្យ។[51] បន្ទាប់មក លោក **លីសាក់** បានលើកឡើងពីកិច្ចប្រជុំជាក់លាក់មួយ ដោយពិភាក្សាពីការពន្យារពេលនៃពិធីបុណ្យខួបបក្សឆ្នាំ១៩៧៦ ពីខែកញ្ញា ដល់ខែតុលា ដើម្បីបញ្ជាក់ពីទំនាក់ទំនងរវាងសេចក្តីសម្រេច ដែលត្រូវបានធ្វើឡើងដោយកម្មាភិបាលថ្នាក់លើ និងការស៊ើបអង្កេតថ្នាក់ក្រោម។[52] នៅក្នុងកិច្ចប្រជុំដដែលនេះ **សុន សេន** បានគាំទ្រឲ្យមានការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុង ដោយអះអាងថា ប្រសិនបើគ្មានការជម្លៀសប្រជាជនទេ "បើយើងទុកប្រជាជនមិនជម្លៀសចេញពីក្រុងច្បាស់ជាមិនបានសុខសាន្តដូចសព្វថ្ងៃទេ។ បើយើងមិនដាច់ខាតធ្វើសហករណ៍ មិនដាច់ខាតធ្វើសង្គមនិយមទេ យើងមិនឈ្នះទេ។" បន្ទាប់មក លោក **លីសាក់** បានដាក់បង្ហាញគំរូនៃរបាយការណ៍កងពលដែលបានផ្ញើឲ្យ **សុន សេន** ប៉ុន្តែត្រូវបានគេផ្ញើបន្តឲ្យមកមេដឹកនាំបក្សផ្សេងៗទៀត ក្នុងនោះមានរូប **នួន ជា** ដើម្បីសុំការអនុញ្ញាត។[53]

ព្រះរាជអាជ្ញា បានបន្តធ្វើបទបង្ហាញពីឯកសារយោធាចាប់ពីឆ្នាំ១៩៧៧។ ឯកសារទាំងនេះមានរបាយការណ៍កងពល និងកិច្ចប្រជុំជាមួយថ្នាក់លើជាច្រើន ដែលរៀបរាប់លម្អិតពីការសម្លាប់បោសសម្អាត ការចាប់ខ្លួន និងការស៊ើបអង្កេតបណ្តាញក្បត់។[54] គាត់ក៏បានដាក់ឯកសារដែលបង្ហាញពីរបៀបដែលរបាយការណ៍នៃកងពលត្រូវបានគេបញ្ជូនបន្តទៅ "អង្គការ" និងសំដៅទៅទួលស្លែង ដូចដែលការបញ្ជានានាពីមជ្ឈិម ត្រូវបានបញ្ជូនបន្តក្នុងកងពលដើម្បីឆ្លើយតបនឹងចម្លើយសារភាពរបស់មន្ទីរ ស-២១។[55] លោក **លីសាក់** បានបញ្ចប់ការដាក់

បង្ហាញឯកសាររបស់គាត់ជាមួយសារទូរលេខមួយពីគោលជំហរចំពោះវៀតណាម ដែលត្រូវបានដាក់ជូនដោយផ្ទាល់ទៅគណៈកម្មកា៨៧០ និងចម្លងជូនទៅ "បង **នួន**"។[56]

### *ខ.១.ក. មតិពីក្រុមការពារក្តី និងការឆ្លើយតបពីព្រះរាជអាជ្ញា*

លោក **សុន អរុណ** មេធាវីជាតិការពារក្តីឲ្យលោក **នួន ជា** បានបញ្ចេញមតិមុនគេ ដោយរម្លឹកតុលាការពីការជំទាស់កាលពីលើកមុនរបស់ **នួន ជា** ពីភាពត្រឹមត្រូវតាមច្បាប់នៃយថាភាពលើបញ្ហាដាក់ជាភស្តុតាងនៃទង់បដិវត្តន៍ ដោយបានចោទថា វៀតណាមអាចកែប្រែទង់បដិវត្តន៍នេះឡើងវិញ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម។[57] មេធាវីការពារក្តីបានស្នើបន្ថែមទៀតថា អង្គជំនុំជម្រះគួរតែកោះហៅអ្នកនិពន្ធទាំងអស់ មានដូចជាសៀវភៅ របាយការណ៍ព័ត៌មាន និងអត្ថបទនានា ដែលសរសេរពីកម្ពុជាប្រជាធិបតេយ្យ ដែលសហព្រះរាជអាជ្ញាបានប្រើប្រាស់ដើម្បីកសាងសំណុំរឿងចោទប្រកាន់កូនក្តីរបស់គាត់។

លោក **ខាណាវ៉ាស** បានកត់សម្គាល់ថា ការធ្វើបទបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា ស្រដៀងនឹងការធ្វើបទបង្ហាញសេចក្តីសន្និដ្ឋានបញ្ចប់ ដោយសារព្រះរាជអាជ្ញាបានរៀបរាប់ជាក់លាក់ ទាក់ទងនឹងការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។ ទោះបីជាលោកបានដឹងថា ប្រព័ន្ធច្បាប់ស៊ីវិលពិចារណាទទួលយកភស្តុតាងគ្រប់ប្រភេទទាំងអស់ក៏ដោយ ក៏លោកបានបញ្ជាក់ថា ភស្តុតាងឯកសារត្រូវបានគេទទួលយកតាមលក្ខណបម្រុងទុក ដោយសារតែឱកាសសួរដេញដោលសាក្សីពាក់ព័ន្ធលើខ្លឹមសារនៃឯកសារទាំងនេះ គឺជាការចាំបាច់ក្នុងការស្តែងឲ្យឃើញពីយថាភាព និងភាពគួរឲ្យទុកចិត្តបាន។ មេធាវី **ហ្គីសសេ** បានគាំទ្រគោលជំហររបស់លោក **ខាណាវ៉ាស** ចំពោះការទទួលយកនៃភស្តុតាងឯកសារក្នុងតុលាការ មានលក្ខណៈទូលំទូលាយ ហើយមិនទាន់មានឱកាសពិភាក្សាដេញដោលលើតម្លៃភស្តុតាងបឋមនៅឡើយទេ។ កញ្ញា **ហ្គីសសេ** មិនបានបង្ហាញឯកសារជាក់លាក់ណាមួយទេ ប៉ុន្តែបានសួរអង្គជំនុំជម្រះពីគោលបំណងផ្នែកនៃសវនាការនេះ (សូមមើលផ្នែកទី៣. ១ ខាងក្រោម)។

លោក **ឌេល លីសាក់** បានឆ្លើយតបវិញថា ការដាក់បង្ហាញឯកសារមិនមានបំណងដាក់ជាសេចក្តីសន្និដ្ឋានបិទទេ ហើយមេធាវីត្រូវបានផ្តល់ឱកាសក្នុងខណៈនេះដើម្បីធ្វើការសង្កេតការណ៍លើឯកសារជាក់លាក់ណាមួយ មិនមែនពិភាក្សាលើភាពទទួលយកបាននៃឯកសារទាំងនេះទេ។ ជាកិច្ចឆ្លើយតបទៅការជំទាស់ដដែលៗរបស់លោក **សុន អរុណ** លោក **លីសាក់** បានរម្លឹកអង្គជំនុំជម្រះថា លោក **គីម វុន** អ្នកដែលបានធ្វើការនៅមន្ទីរបោះពុម្ពទង់បដិវត្តន៍បានបញ្ជាក់រួចជាស្រេចនូវយថាភាពនៃទស្សនាវដ្តីទាំងនេះក្នុងសក្ខីកម្មរបស់គាត់។[58]

### *ខ.២. ការធ្វើបទបង្ហាញរបស់ព្រះរាជអាជ្ញាលើការជម្លៀសប្រជាជនដំណាក់កាលទី១ និង ទី២ និងទួលពោធិ៍ជ្រៃ*

ព្រះរាជអាជ្ញាជាតិ **វ៉េង ហ៊ត់** បានចាប់ផ្តើមធ្វើបទបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា លើបញ្ហានៃការជម្លៀសប្រជាជនដោយបង្ខំដំណាក់កាលទី១ នៅជុំវិញថ្ងៃ (១៧ មេសា ១៩៧៥) និងដំណាក់កាលទី២ (ចាប់

ផ្ដើមនៅចុងឆ្នាំ១៩៧៥) និងទីតាំងពិឃាតនៅទួលពោធិជ្រៃ នៅខេត្តពោធិ៍សាត់។[59] បន្ទាប់មក ព្រះរាជអាជ្ញាអន្តរជាតិ **វេយ័ន់រ** បានឡើងធ្វើបទបង្ហាញឯកសាររហូតដល់ការបញ្ចប់សវនាការនៅពេលរសៀលថ្ងៃព្រហស្បតិ៍។ លោក **វេយ័ន់រ** បានដាក់បង្ហាញឯកសារតាមលំដាប់ពេលវេលា រួមទាំងឯកសារវីដេអូខ្លីៗ ដើម្បីបន្ថែមព័ត៌មានដល់ឯកសារពាក់ព័ន្ធ។ ក្រុមការពារក្ដី បានលើកឡើងសេចក្ដីជំទាស់របស់ពួកគេ បន្ទាប់ពីការបញ្ចប់បទបង្ហាញរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

### *ខ.២.ក. ឯកសារពាក់ព័ន្ធនឹងការជួលរលំភ្នំពេញ និងការជម្លៀសប្រជាជនដោយបង្ខំក្នុងដំណាក់កាលទី១*

លោក **វេយ័ន់រ** បានចាប់ផ្ដើមដាក់បង្ហាញរបស់គាត់ជាមួយនឹងឯកសារ ដែលធ្វើឡើងចាប់ពីខែកុម្ភៈ ដល់ថ្ងៃ១៦ មេសា ឆ្នាំ១៩៧៥។ គាត់បានបង្ហាញរបាយការណ៍ បានមកពីបណ្ណសារអាមេរិកពីស្ថានការណ៍នៅប្រទេសកម្ពុជា រួមទាំង បញ្ហាទី១នៅខែកុម្ភៈ ឆ្នាំ១៩៧៥ និងបញ្ហាទី២ពីសភាប្រជាជាតិកម្ពុជា ដែល **ខៀវ សំផន** បានធ្វើជាអធិបតេយ្យ និងនិយាយពីភាពចាំបាច់ក្នុងការសម្លាប់ "ជនក្បត់ទាំងប្រាំពីរ"។[60] របាយការណ៍ផ្សេងៗទៀតបានរៀបរាប់ពីការចែកចាយជំនួយស្បៀងអាហាររបស់អាមេរិកឲ្យប្រជាជននៅទីក្រុងភ្នំពេញ ការកើនឡើងជនភៀសខ្លួនក្នុងទីក្រុង និងការបន្តវាយលុកចូលទីក្រុងរបស់កងទ័ពខ្មែរក្រហម។[61] លោក **វេយ័ន់រ** បានបញ្ចូលរបាយការណ៍ពីការផ្សព្វផ្សាយព័ត៌មានបរទេស លើសេចក្ដីភ័យខ្លាចរបស់ប្រធានាធិបតីសហរដ្ឋអាមេរិក **ចេរ៉ាល់ ហ្វត** (*President Gerald Ford*) ពីការមកដល់នៃការសម្លាប់បង្ហូរឈាម និងការបដិសេធលើបញ្ហានេះរបស់សមាជិកម្នាក់នៃរណសិរ្សរួបរួមជាតិកម្ពុជា ទោះបីជាវាបានដកស្រង់ពីការប្រកាសរបស់ **ខៀវ សំផន** ឲ្យមានចលនាតស៊ូកាន់តែខ្លាំងឡើង។[62] បន្ទាប់មក គាត់បានដាក់បង្ហាញរបាយការណ៍របស់ក្រសួងការបរទេស របាយការណ៍ផ្សព្វផ្សាយព័ត៌មានបរទេស២បន្ថែមទៀត និងវីដេអូមួយ ដែលស្ដែងឲ្យឃើញពីកំណើននៃការគ្រប់គ្រងរបស់ខ្មែរក្រហម និងជំហាននយោបាយចុងក្រោយរបស់សាធារណរដ្ឋខ្មែរ។[63] ព្រះរាជអាជ្ញាបានបន្តដាក់របាយការណ៍របស់ផ្សព្វផ្សាយព័ត៌មានបរទេសលើបញ្ហានេះ ដោយវិភាគលើការប៉ុនប៉ងមិនបានសម្រេចរបស់ **ឡុង បូរេត** ក្នុងការចរចារ និងការបដិសេធរបស់ **ខៀវ សំផន** ដោយបាននិយាយថា សេចក្ដីសម្រេចលើជនក្បត់ទាំងប្រាំពីរនេះ ត្រូវបានសម្រេចរួចហើយ។[64] របាយការណ៍ផ្សេងៗទៀតបានមកពីឯកសារតែមួយពាក់ព័ន្ធនឹងការវាយចូលរបស់កងទ័ពខ្មែរក្រហមមកទីក្រុងភ្នំពេញ ក្នុងខណៈដែលពួកគេបានកាន់កាប់ស្រុក ឫស្សីកែវ ទួលគោក និង ពោធិ៍ចិនតុង រួមទាំងព្រលានយន្តហោះផងដែរ។[65] លោក **វេយ័ន់រ** បានអានឮៗ ពីការផ្សព្វផ្សាយតាមវិទ្យុមួយចេញពីឯកសារតែមួយ ទាក់ទងនឹងសំបុត្រមួយពីព្រះអង្គម្ចាស់ **សិរិមតៈ** ទៅកាន់ប្រធានាធិបតេយ្យសហរដ្ឋអាមេរិក **ហ្វត** និងអគ្គរដ្ឋទូតថា "មរណភាពរបស់ប្រជាជនកម្ពុជានាពេលបច្ចុប្បន្នទាំងអស់ គឺថាស្ថិតនៅលើមនសិការរបស់ប្រជាជនអាមេរិក។"[66]

ព្រះរាជអាជ្ញា បានបន្តធ្វើបទបង្ហាញឯកសារជាមួយនឹងព្រឹត្តិការណ៍ ដែលបានកើតឡើងនៅថ្ងៃ១៧ មេសា ឆ្នាំ១៩៩៥ ដោយប្រើប្រាស់របាយការណ៍ដដែល បានផ្សព្វផ្សាយព័ត៌មានបរទេស ដែលបានថតចម្លងការផ្សព្វផ្សាយវិទ្យុពីការវាយបែកភ្នំពេញពីគ្រប់ទិសទី សំណើពីអំពាវនាវរបស់ស្ថាប័នព្រះពុទ្ធសាសនាសំខាន់ៗឲ្យបញ្ឈប់ការបាញ់បោះ សេចក្តីសម្រេចជាបន្តបន្ទាប់របស់កងទ័ពខ្មែរក្រហមឲ្យឈប់បាញ់ប្រហារ និងសេចក្តីឆ្លើយតបទាន់ហន់ពីខ្មែរក្រហម៖ "យើងហ្នឹងមិនមក ចរចាជាមួយពួកវាឡើយ យើងកំពុងតែវាយចូលទីក្រុងភ្នំពេញ។"[67] បន្ទាប់មក លោក **រេយ៍ន័រ** បានប្តូរការសង្កេតលើអ្នករាយការណ៍ **ហ្សង់ហ្សាក កាហ្សូ** (*Mr. Jean-Jacques Cazaux*) ដែលរាយការណ៍ពីការបញ្ជាឲ្យប្រជាជននៅខាងជើងទីក្រុងភ្នំពេញឲ្យចាកចេញពីទីក្រុង ក្នុងខណៈដែលអតីតមន្ត្រីខ្មែរសាធារណរដ្ឋ បានដាក់អាវុធចុះចាញ់ដោយខ្លួនឯង។[68] បន្ទាប់មក ព្រះរាជអាជ្ញាបន្តទៅសារទូរលេខស្ថានទូតបារាំងនៅភ្នំពេញ និងក្រសួងការបរទេសនៅទីក្រុងប៉ារីសពីសំណើរបស់សម្តេច **សិរិមតៈ** និង **អ៊ុំ ប៊ុនហោ** ពីសិទ្ធិជ្រកកោន ក៏ដូចជា ការសង្កេតរបស់កុងស៊ុល **ហ្សង់ ឌីរ៉ាក់** (*Consul Jean Dyrac*) ពីការវាយបែកទីក្រុងភ្នំពេញ និងការមកដល់របស់មេដឹកនាំខ្មែរក្រហម។[69]

លោក **រេយ៍ន័រ** បានបន្តភ្លាមលើព្រឹត្តិការណ៍នៅក្រោយថ្ងៃ ១៧ មេសា ១៩៧៥។ គាត់បានដកស្រង់របាយការណ៍ជាប្រចាំរបស់លោក **កាហ្សូ** នៅថ្ងៃបន្ទាប់ ដែលបានរៀបរាប់ពីការធ្វើដំណើរជាបន្តបន្ទាប់របស់អ្នកភៀសខ្លួនទៅកាន់ទិសខាងជើង ការលួច និងដុតផ្ទះ ក៏ដូចជាការជម្លៀសនៅមន្ទីរពេទ្យកាល់ម៉ែត្រ។ **កាហ្សូ** បានបន្តរៀបរាប់ពីការប្រកាសតំបន់សុវត្ថិភាព អន្តរជាតិនៅស្ថានទូតបារាំង ដែលកុងស៊ុល **ឌីរ៉ាក់** បានធានាថាជនជាតិខ្មែរនឹងចាកចេញពីអគារនេះ។[70] លោក **រេយ៍ន័រ** បានត្រឡប់មករកសេចក្តីចងក្រងនៃសម្រង់អត្ថបទពីកាសែត **ថាមស៍ឡុងដុន** ដែលបានរៀបរាប់ "ក្នុងសង្គ្រាមរយៈពេល៥ឆ្នាំនេះ ជាទុក្ខវេទនាដ៏ធ្ងន់ធ្ងរបំផុតនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដែលធ្លាប់បានជួបប្រទះ ... ទីក្រុងទាំងមូលកំពុងក្លាយជាកន្លែងស្ងប់ស្ងាត់គ្មានមនុស្សរស់នៅ ទោះជាមនុស្សចាស់ ជាអ្នកជំងឺក្តី ជាមនុស្សទន់ខ្សោយ ជាអ្នកអត់ឃ្លាន និងជាក្មេងកំព្រា ក៏ពួកគេមិនត្រូវបានលើកលែងដែរ។"[71] បន្ទាប់មក ព្រះរាជអាជ្ញា បានដាក់បង្ហាញឯកសារទាក់ទងនឹងព្រឹត្តិការណ៍នៅថ្ងៃ ១៩ មេសា ឆ្នាំ១៩៧៥ ដែលសម្តែងពីការព្រួយបារម្ភពីវាសនារបស់មេដឹកនាំខ្មែរសាធារណរដ្ឋ ដែលកំពុងស្ថិតនៅភ្នំពេញនៅឡើយបន្ទាប់ពីការដួលរលំភ្នំពេញ។[72] លោក **រេយ៍ន័រ** ក៏បានដកស្រង់ការប្រកាសផ្សព្វផ្សាយមួយពីវិទ្យុសម្លេងរណសិរ្សរួបរួមជាតិ ដែលប្រកាសពីគោលដៅរបស់ខ្លួនក្នុងការកម្ចាត់ចោលជនក្បត់ទាំងប្រាំពីរនាក់ និង "កសាងកម្ពុជាថ្មី ដែលឯករាជ្យ សន្តិភាព អព្យាក្រឹត អធិបតេយ្យ ប្រជាធិបតេយ្យ និងមានការជឿនលឿននៅក្នុងបូរណភាពដែនដីរបស់ខ្លួន" ហើយក៏បានរៀបរាប់លម្អិតពីតំបន់រំដោះថ្មីៗ រួមទាំងទីរួមខេត្តនានា។

នៅថ្ងៃទី ២០ មេសា ១៩៧៥ លោក **ឌីរ៉ាក់** បានផ្ញើសំណើរបស់គាត់ទៅកាន់ក្រសួងការបរទេសសម្រាប់ការជម្លៀសចេញជាបន្ទាន់ ពីព្រោះវត្តមានរបស់បារាំងគ្មានប្រយោជន៍អ្វីទៀតទេ ហើយពួកគេបានក្លាយទៅជាសាក្សីនៃព្រឹត្តិការណ៍ដ៏គួរឲ្យខ្មាសអៀន។[73] គាត់ក៏បានរាយការណ៍ពីជនភៀសខ្លួនចាប់ផ្តើមចាកចេញពីបរិវេណ

ស្ថានទូត រួមទាំងព្រះអង្គម្ចាស់ **សិរិមតៈ** ប្រគល់ខ្លួនចុះចាញ់ជាអ្នកទោសនៅព្រឹកថ្ងៃស្អែក។ លោក **វេយ៍ន័រ** បានបន្តប្រើប្រាស់ការរាយការណ៍ជាប្រចាំរបស់លោក **កាហ្សូ** ដែលបានរៀបរាប់ពីការភ័យស្លន់ស្លោជាសាធារណៈ ក្នុងខណៈដែលប្រជាពលរដ្ឋខ្មែរខ្លះបានជម្នះសេចក្ដីភ័យខ្លាចនេះ ហើយអ្នកខ្លះទៀតបានស្នើសុំរៀបការជាមួយប្រជាពលរដ្ឋបារាំង។ នៅថ្ងៃទី ២១ មេសា គាត់បានរាយការណ៍ថា មានជនភៀសខ្លួនខ្មែរជាច្រើនបានចាកចេញ ហើយអ្នកខ្លះបានសុំប្រធានវេជ្ជបណ្ឌិតពេទ្យកាល់ម៉ែត្រឲ្យចាក់ថ្នាំសម្លាប់ពួកគាត់ និងកូនៗផងដែរ។ បន្ទាប់មក ព្រះរាជអាជ្ញា បានដកស្រង់ការប្រកាសផ្សព្វផ្សាយវិទ្យុមួយដែល **ខៀវ សំផន** បានប្រកាស "ជ័យជម្នះដ៏មហាអស្ចារ្យ ដែលបានបើកផ្លូវដ៏ភ្លឺស្វាង និងត្រឹមត្រូវបំផុតក្នុងការដឹកនាំប្រជាជនកម្ពុជា។"[74] លោក **វេយ៍ន័រ** បានលើកយកអត្ថបទមួយដែលនិយាយពីការទម្លាក់អាវុធចុះចាញ់របស់អតីតមេដឹកនាំខ្មែរសាធារណរដ្ឋ ការផ្លាស់ប្ដូរប្រទេសកម្ពុជាទៅជារដ្ឋឯកបក្សកុម្មុយនីស្ត និងការខិតខំប្រឹងប្រែងជម្រះចោលប្រពៃណីចាស់ៗ និងការជម្លៀសប្រជាជនដោយបង្ខំឲ្យរស់នៅជាសហករណ៍។[75]

ព្រះរាជអាជ្ញា ក៏បានដាក់បង្ហាញរបាយការណ៍ផ្សព្វផ្សាយព័ត៌មានបរទេសមួយ ចុះថ្ងៃ២៦ ខែមេសា ពាក់ព័ន្ធនឹងបទសម្ភាសន៍អ្នកកាសែតជនជាតិបារាំងម្នាក់ជាមួយជនភៀសខ្លួន ដែលមកដល់ប្រទេសថៃក្រោយពីគាត់ត្រូវគេបានជម្លៀស។ គាត់បានរាយការណ៍ថា បានឃើញផ្ទាល់ភ្នែកការសម្រិតសម្រាំង និងចាប់ខ្លួនអ្នកគាំទ្ររបបបរាជ័យ **លន់ នល់** អ្នកជំនួញស្ដុកស្ដម និងព្រះសង្ឃ ក្នុងខណៈអ្នកផ្សេងទៀត បានហៅជនជាតិចាមអ៊ីស្លាមថា ជាជនរងគ្រោះទីមួយនៃការសម្លាប់បោសសម្អាតរង្គាលប្រឆាំងនឹងសាសនា។[76] បន្ទាប់មក លោក **វេយ៍ន័រ** បានដាក់បង្ហាញរបាយការណ៍របស់លោក **កាហ្សូ** ចាប់ពីថ្ងៃទី២៦ ដល់ថ្ងៃ៣០ ខែមេសា នៅក្រោយពេលដែលមេបញ្ជាការយោធានៅភ្នំពេញបានសម្រេចចិត្តជម្លៀសជនបរទេសទាំងអស់ឲ្យទៅប្រទេសថៃ តាមឡានដឹកទំនិញឲ្យអស់នៅបំណាច់ខែនេះ។ លោក **វេយ៍ន័រ** បានបន្តបញ្ជាត្រង់នេះជាមួយនឹងអត្ថបទកាសែត **ថាមស៍** ចុះថ្ងៃទី១ ខែឧសភា "យើងវង្វេងវង្វាន់ និងច្របូកច្របល់" ដែលអ្នកកាសែតបានរៀបរាប់ថា ជាការធ្វើដំណើរពីរថ្ងៃដ៏គួរឲ្យធុញទ្រាន់ជាទីបំផុត ដែលបង្កឲ្យមានចំណុចដែលនឹកស្មានមិនដល់សោះថា នៅក្រៅទីក្រុងភ្នំពេញស្ទើរតែនៅគ្រប់ទីប្រជុំជនភូមិ និងតាមក្រុមតូចៗដែលមិនព្រមចុះចូលជាមួយបក្សកុម្មុយនីស្ត បានជម្លៀសខ្លួនចេញទៅតាមទីជនបទ។"[77]

បន្ទាប់មក ព្រះរាជអាជ្ញាបានបង្ហាញសារទូរលេខដ៏វែងមួយចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៧៥ ពីស្ថានទូតបារាំងនៅប្រទេសថៃមកកាន់ក្រសួងការបរទេសបារាំង ដែលរាយការណ៍ពីសក្ខីកម្មរបស់ឧត្តមសេនីយ៍ត្រី **សរ ប៊ុន** នៅថ្ងៃទី២៧ ខែឧសភា។ ក្នុងឋានៈជាអតីតឧត្តមសេនីយ៍ថ្នាក់ខ្ពស់ក្នុងរបបខ្មែរសាធារណរដ្ឋ គាត់បានរត់គេចពីការចាប់ខ្លួន និងបានមកដល់ប្រទេសថៃក្រោយពីបានដើរអស់រយៈពេល៣៩ថ្ងៃ តាមទិសខាងជើងនៃប្រទេសកម្ពុជា។ គាត់បានអះអាងថា គាត់បានឃើញការជម្លៀសប្រជាជន មិនមែនមានត្រឹមតែនៅភ្នំពេញទេ ប៉ុន្តែរួមទាំងប្រជាជនទាំងអស់នៅតាមបណ្ដោយផ្លូវជាតិលេខ៦ ចម្ងាយ៤០០គីឡូម៉ែត្រ ហើយគាត់បញ្ចេញយោបល់ថា ខ្មែរក្រហមចង់ដាក់ទោសប្រជាជនទីក្រុង ដែលមិនស្វាគមន៍បដិវត្តន៍។ ចំពោះប្រធានបទប្រហារជីវិតវិញ លោក **សរ**

**ប៊ុន** បានធ្វើចំណាត់ថ្នាក់បី៖ “ការសម្លាប់ភ្លាមៗនៅនឹងកន្លែង” ចំពោះអ្នកដែលមិនគោរពតាមបទបញ្ជាឲ្យជម្លៀសចេញ “ការសម្លាប់ជាប្រព័ន្ធ” ដោយការប្រមូលផ្តុំអតីតមន្ត្រីយោធា និង “ការសម្លាប់ដោយផ្តាច់ជីវិត សន្សឹមៗ” អ្នកជម្លៀសត្រូវបានគេបង្ខំឲ្យធ្វើការក្នុងស្ថានភាពយ៉ាប់យ៉ឺនដោយមិនមានអាហារគ្រប់គ្រាន់។[78]

### *ខ.២.ខ. ឯកសារពាក់ព័ន្ធនឹងទីតាំងប្រហារជីវិតនៅទួលពោធិ៍ជ្រៃ*

បន្ទាប់មក លោក **រេយ័ន័រ** បានបន្តដាក់បង្ហាញឯកសារទាក់ទងនឹងវាលពិឃាតនៅទួលពោធិ៍ជ្រៃ ក្នុងខេត្តពោធិ៍សាត់។ ដំបូងឡើយ គាត់បានអានសម្រង់សង្ខេបចេញពីអត្ថបទកាសែត រួមទាំងពាក្យចចាមអារ៉ាមថា ខ្មែរក្រហមបាននឹងកំពុងប្រហារជីវិតមន្ត្រីយោធានៅកន្លែងបណ្តុះដើមកៅស៊ូនៅជាយក្រុងភ្នំពេញ។ គាត់ក៏បានដាក់បង្ហាញសេចក្តីប្រកាសព័ត៌មានរបស់**អង្គការលើកលែងទោសអន្តរជាតិ** (*Amnesty International Press*) ដែលអំពាវនាវឲ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ១៩៧៥ និង ១៩៧៦។[79] លោក **រេយ័ន័រ** បានបញ្ចប់ផ្នែកនៃការធ្វើបទបង្ហាញឯកសារនេះជាមួយនឹងវីដេអូឯកសារដ៏វែងមួយ ដែលមានចំណងជើង “មួយថ្ងៃនៅទួលពោធិ៍ជ្រៃ។”[80] វីដេអូនេះ មានបទសម្ភាសន៍ជាមួយអតីតទាហាន និងអ្នកភូមិ ដែលបានពន្យល់ពីរបៀបដែលជនរងគ្រោះបានដឹកយកមកទីតាំងសម្លាប់ ដោយការបោកបញ្ឆោតថាមកជួប សម្តេច **សីហនុ** ឬ អង្គការ ហើយបន្ទាប់មកត្រូវបានប្រហារជីវិត។ សាក្សីក្នុងបទសម្ភាសន៍នេះ បានរៀបរាប់ពីរបៀបដែលជនរងគ្រោះត្រូវបានចងដៃ និងបាញ់សម្លាប់។ អតីតទាហានខ្មែរក្រហមម្នាក់បាននិយាយថា យ៉ាងហោចណាស់មានមនុស្សចាប់ពី ៨០០០នាក់ទៅ ៩០០០នាក់ ត្រូវបានសម្លាប់នៅទីនោះ។

### *ខ.២.គ. ឯកសារពាក់ព័ន្ធនឹងការជម្លៀសដោយបង្ខំដំណាក់កាលទី២*

ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដំណាក់កាលទី២ ព្រះរាជអាជ្ញា **រេយ័ន័រ** បានប្រើប្រាស់ឯកសារគណៈអចិន្ត្រៃយ៍ជាច្រើននៅក្នុងការដាក់បង្ហាញឯកសាររបស់គាត់។ គាត់បានចាប់ផ្តើមជាមួយនឹងកំណត់ហេតុនៃទស្សនៈកិច្ចរបស់គណៈអចិន្ត្រៃយ៍ទៅភូមិភាគពាយព្យនៅចាប់ពីថ្ងៃទី២៤ ដល់ ២៧ ខែសីហា ឆ្នាំ១៩៧៥ ដែលរៀបរាប់ពីលក្ខណៈសម្បត្តិរបស់ភូមិភាគនេះថា ជាតំបន់ដីមានជីវជាតិសម្រាប់ធ្វើកសិកម្ម ដែលតម្រូវឲ្យមានកម្លាំងពលកម្មមនុស្សជាច្រើន ដើម្បីទទួលបានជោគជ័យនៃគោលនយោបាយខ្លួនឧបត្ថម្ភខ្លួន ហើយឯកសារដដែល ក៏បានរៀបរាប់ពីទុក្ខវេទនារបស់ប្រជាជនថ្មីពីការខ្វះស្បៀងអាហារ និងថ្នាំសង្កូវនៅទីនោះក៏ដោយ។[81] បន្ទាប់មក ព្រះរាជអាជ្ញាបានដាក់បង្ហាញឯកសារបក្សកុម្មុយនីស្តមួយច្បាប់ ដែលនិយាយពីការខ្វះខាតស្បៀង និងសេចក្តីចាំបាច់ក្នុងការកសាងទំនប់ទឹកបន្ថែម ហើយនិងការចុះបញ្ជីតម្រូវការឲ្យមានចំនួនកម្មករបន្ថែមសម្រាប់ភូមិភាគ និងស្រុកនានា។[82] ក្រោយមកទៀត លោក **រេយ័ន័រ** បានបង្ហាញរបាយការណ៍មួយនៅខែមិថុនា ឆ្នាំ ១៩៧៧ ពីការជម្លៀសប្រជាពលរដ្ឋនៅតាមស្រុកនីមួយៗក្នុងតំបន់លេខ៥នៃភូមិភាគពាយព្យ បន្ទាប់ពីការជម្លៀសប្រជាជនដំណាក់កាលទី២។ វាបានកត់សម្គាល់ថា ស្រុកព្រះនេត្រព្រះ មាន១៥០គ្រួសារមុនថ្ងៃទី១៧

មេសា ១៩៧៥ ប៉ុន្តែក្រោយមកមានប្រជាជន ៧០ ០០០នាក់បានមកពីភ្នំពេញ ទោះបីជានៅទីនោះជួបគ្រោះអត់ឃ្លានដ៏អាក្រក់បំផុតក៏ដោយ ដែលឆ្នាំទៅមិញបានសម្លាប់មនុស្សជាង ២០ ០០០នាក់។[83]

បន្ទាប់មក លោក **រេយ៍ន័រ** បានណែនាំអត្ថបទមួយបោះពុម្ពផ្សាយនៅក្នុង **ហ្វាអិសស្ទើន អេកូណូមិក រីវ្យូ** (*Far Eastern Economic Review*) នៅខែមករា ឆ្នាំ១៩៧៦ ដែលបំភ្លឺពីការសង្កត់ធ្ងន់របស់បក្សកុម្មុយនីស្តកម្ពុជាលើភាពចាំបាច់នៃការជម្លៀសប្រជាជនសម្រាប់ទិន្នផលស្បៀងអាហារ។ យោងតាមកិច្ចសម្ភាសន៍ជាមួយជនភៀសខ្លួននៅប្រទេសថៃ អ្នកនិពន្ធបានសរសេរថា កត្តាចម្បងរបស់របបនេះគឺទិន្នផលស្រូវអង្ករ ដោយសារអង្ករអាចយកទៅទិញវត្ថុធាតុដើមផ្សេងៗទៀតបាន។ ហេតុផលនេះក៏មាននៅក្នុងសេចក្តីថ្លែងការណ៍របស់លោក **អៀង សារី** ដែលថាកម្ពុជាប្តេជ្ញាចិត្តក្លាយជា ខ្លួនឧបត្ថម្ភខ្លួនផ្នែកស្រូវអង្ករ ដែលតម្រូវឲ្យមានការជម្លៀសប្រជាជនជាលើកទី២។[84] អត្ថបទមួយផ្សេងទៀតបានរាយការណ៍ថា "ប្រជាជនកម្ពុជារាប់សែននាក់ត្រូវបានជម្លៀសដោយបង្ខំសាជាថ្មី ពីទីកន្លែងមួយទៅទីកន្លែងមួយថ្មីទៀតក្នុងប្រទេស ហើយមានអ្នកជម្លៀសមួយចំនួនធំ បានបាត់បង់ជីវិតក្នុងដំណើរជម្លៀសដ៏សែនលំបាកនោះ។ ជាទូទៅប្រជាជនត្រូវបានគេជម្លៀសដោយបង្ខំឆ្ពោះទៅកាន់តំបន់ដែលពុំសូវមានប្រជាជន និងដែលមានការអភិវឌ្ឍតិចតួចនៅខេត្តបាត់ដំបង។"[85] ជាថ្មីម្តងទៀត លោក **រេយ៍ន័រ** បានដកស្រង់របាយការណ៍របស់អង្គការលើកលែងទោសអន្តរជាតិ ដែលបាននិយាយពីការបាត់ខ្លួនមនុស្សដោយសារការជម្លៀសដោយបង្ខំឲ្យទៅធ្វើការនៅតំបន់ដាច់ស្រយាល។

### *ខ.៣. ការដាក់បង្ហាញឯកសារដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី*

ក្រោយពីការពិភាក្សាដេញដោលជាច្រើនក្នុងសប្តាហ៍នេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានស្នើដាក់សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដោយសារតែពួកគេមិនទាន់បានរៀបចំរួចរាល់សម្រាប់ការធ្វើបទបង្ហាញដាក់ឯកសារ នៅពេលសហព្រះរាជអាជ្ញាបានបញ្ចប់ការដាក់បង្ហាញឯកសារ។ លោកស្រី **អេលីហ្សាបេត ស៊ីម៉ុនណូ ហ្វត** បានពិភាក្សាលើប្រធានបទរចនាសម្ព័ន្ធយោធារបស់កម្ពុជាប្រជាធិបតេយ្យ ចំណែកឯ លោក **ពេជ អង្គ** បានធ្វើបទបង្ហាញឯកសារភាគច្រើនលើការជម្លៀសប្រជាជនដោយបង្ខំនៅដំណាក់កាលទី១ និងទី២ និងការសម្លាប់នៅទួលពោធិ៍ជ្រៃ។

### *ខ.៣.ក. ឯកសារពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា*

លោកស្រី **ស៊ីម៉ុនណូហ្វត** បានដាក់បង្ហាញសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលលោកស្រីបានពន្យល់ថា "វាពាក់ព័ន្ធនឹងមន្ទីរសន្តិសុខ ដែលបង្កើតជាធាតុផ្សំនៃរចនាសម្ព័ន្ធយោធា។"[86] វានឹងមិនមានភាពច្បាស់លាស់លើបញ្ហារចនាសម្ព័ន្ធយោធាទេ ដោយសារតែសេចក្តីថ្លែងការណ៍ដែលត្រូវបានជ្រើសរើសភាគច្រើនផ្តោតចំណាប់អារម្មណ៍លើបទពិសោធន៍នៅមន្ទីរសន្តិសុខ និងហេដ្ឋារចនាសម្ព័ន្ធមន្ទីរឃុំឃាំង ជាជាងបញ្ហាយោធា។ លោកស្រី បានបង្ហាញសេចក្តីថ្លែងការណ៍មួយរបស់ជនរងគ្រោះពីការជម្លៀសដោយបង្ខំចេញពីកំពង់

សោម ការចាប់ខ្លួនរបស់គ្រួសារគាត់ និងការឃុំឃាំងរបស់ពួកគេនៅគុកតានី ក្នុងខេត្តកំពត។ ឯកសារមួយផ្សេងទៀត បានបង្ហាញពីការចាប់ខ្លួនដើមបណ្តឹងរដ្ឋប្បវេណី ដោយសារជាអតីតគាត់មានតួនាទីជាគ្រូបង្រៀន ត្រូវបានធ្វើការអប់រំកែប្រែឡើងវិញ និងឲ្យធ្វើការងារការកសាងទំនប់ទឹក។[87] លោកស្រី បានបញ្ចប់ការដាក់ឯកសារលើរចនាសម្ព័ន្ធឃោធាដោយរៀបរាប់ឈ្មោះមន្ទីរសន្តិសុខផ្សេងៗជុំវិញប្រទេស ដែលដើមបណ្តឹងរដ្ឋប្បវេណីបានឃុំខ្លួន។[88]

### ខ.៣.ខ. ឯកសារពាក់ព័ន្ធនឹងការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ

សេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើន បានបង្ហាញពីបទពិសោធន៍ស្រដៀងគ្នាក្នុងអំឡុងពេលជម្លៀសចេញពីភ្នំពេញ ដោយជនរងគ្រោះបានចាកចេញពីផ្ទះសម្បែងរបស់ពួកគេ ដោយយល់ថាពួកគេនឹងអាចត្រឡប់មកវិញក្នុងរយៈពេលបីថ្ងៃវិញ។ អ្នកខ្លះក៏បានរៀបរាប់ពីការសម្រិតសម្រាំង និងការបាត់ខ្លួនជាបន្តបន្ទាប់នៃទាហាន និងមន្ត្រីខ្មែរសាធារណរដ្ឋ។ ក្រៅពីបញ្ហាទូទៅនៃការងារលំបាកលំបិន និងកង្វះខាតស្បៀងអាហារ និងថ្នាំសង្កូវ មានសេចក្តីថ្លែងការណ៍ភាគច្រើនរបស់ដើមបណ្តឹងរដ្ឋប្បវេណី បានរៀបរាប់ពីប្រជាជនមូលដ្ឋាន ហើយការឃ្លាំមើល និងការរើសអើងរបស់កម្មាភិបាលខ្មែរក្រហម។ ក្រោយពីបានបរិយាយលម្អិតពីរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណីបីនាក់មក[89] លោកស្រី **ស៊ីម៉ុនណូហ្វត** បានបញ្ចប់ផ្នែកដាក់បង្ហាញឯកសាររបស់លោកស្រី ដោយរៀបរាប់ឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងបទពិសោធន៍ជម្លៀសដោយបង្ខំរបស់ពួកគេ។[90]

ជាកិច្ចបន្ត លោក **ពេជ អង្គ** បានដាក់បង្ហាញសេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២៥ ពីការជម្លៀសប្រជាជនដោយបង្ខំ និងទួលពោធិ៍ជ្រៃ។ ដើមបណ្តឹងរដ្ឋប្បវេណីមួយរូប ជាជនភៀសខ្លួននៅក្នុងភ្នំពេញគេចវេសពីពីការវាយចូលរបស់កងកម្លាំងខ្មែរក្រហមក្នុងឆ្នាំ១៩៧៥ ត្រូវបានគេជម្លៀសទៅខេត្តកណ្តាល ហើយបានប្រទះឃើញការបាញ់ប្រហារលើអ្នកដែលមិនព្រមចាកចេញពីភ្នំពេញ។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតបានរម្លឹកពីសម្តីរបស់ខ្មែរក្រហមដែលបាននិយាយថា អ្នកភ្នំពេញត្រូវចាកចេញ ពីព្រោះពួកគេត្រូវការបោសសម្អាតខ្មាំង ហើយអ្នកដែលបដិសេធមិនព្រមចាកចេញនឹងត្រូវបានចាត់ទុកថាជាខ្មាំង ហើយដូចនេះនឹងត្រូវបានបាញ់សម្លាប់ចោល។ ដើមបណ្តឹងរដ្ឋប្បវេណីទីបី ក៏ត្រូវបានជម្លៀសចេញពីភ្នំពេញផងដែរ ដោយសារតែមានការផែកផេរប្រវត្តិរូបម្តងហើយម្តងទៀត សាច់ញាតិរបស់គាត់ត្រូវបានសម្លាប់ជាបន្តបន្ទាប់ផងដែរ រួមទាំង ឪពុក បងប្អូនប្រុស បងប្អូនស្រី ក្មួយប្រុស ក្មួយស្រី និងក្រុមគ្រួសាររបស់ប្តីគាត់។ គាត់បានពន្យល់ថា "គិតទៅទ្រឹស្តី និងការអនុវត្តន៍ជីកស្មៅត្រូវជីកទាំងឫស ពិតជាត្រឹមត្រូវមែន។"[91]

បន្ទាប់មក លោក **ពេជ អង្គ** បានដាក់បង្ហាញសេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ។ ទោះបីជាសេចក្តីថ្លែងការណ៍ខ្លះទាក់ទងនឹងទួលពោធិ៍ជ្រៃ បានអះអាងថា អតីតមន្ត្រី និងទាហាន **លន់ នល់** ត្រូវបានសម្លាប់នៅទីនោះក៏ដោយ អ្នកខ្លះបាននិយាយសំដៅលើការសម្លាប់នៅខេត្ត

ពោធិ៍សាត់ ប៉ុន្តែមិនត្រូវបានភ្ជាប់ទៅនឹងទីតាំងសម្លាប់នៅទួលពោធិ៍ជ្រៃឲ្យបានជាក់លាក់ទេ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានដកស្រង់សេចក្តីថ្លែងការណ៍ដែលបាននិយាយពីរបៀបដែលខ្មែរក្រហមបានវាយកាន់កាប់ទីរួមខេត្តពោធិ៍សាត់នៅខែមេសា ឆ្នាំ១៩៧៥ ហើយក្នុងខណៈដែលប្រជាជនទូទៅត្រូវបានប្រាប់ឲ្យចាកចេញ ក៏ឃើញមាន អតីតមន្ត្រី វេជ្ជបណ្ឌិត និងគ្រូបង្រៀន ត្រូវបានស្នើសុំឲ្យបង្ហាញខ្លួន។ មានព័ត៌មានមួយទៀត បាននិយាយជាក់លាក់ថា ក្រុមអតីតមន្ត្រីនេះត្រូវបានគេដឹកតាមឡានដឹកទំនិញ ហើយនៅទីបំផុតក៏ត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃ។ សេចក្តីថ្លែងការណ៍ចុងក្រោយ បានពិភាក្សាពីការតាំងទីលំនៅថ្មីពីភ្នំពេញទៅខេត្តពោធិ៍សាត់ ដែលជាកន្លែងឪពុកម្តាយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានសម្លាប់ដោយសារលួចអាហារ។ អ្នកស្រីត្រូវបានខ្មែរក្រហមចាប់បាន ហើយត្រូវបានរំលោភដោយទាហានខ្មែរក្រហមទាំងអស់ ពេលអ្នកស្រីកំពុងលួចមើលហេតុការណ៍នៃការសម្លាប់របស់ឪពុកខ្លួន។ ដំបូងឡើយ គាត់ត្រូវបានប្រាប់ឲ្យលុតជង្គង់នៅមុខរណ្តៅមុននឹងគាត់ត្រូវបានគេវាយសម្លាប់។[92]

### *ខ.៤. មតិយោបល់ពីក្រុមការពារក្តី និងការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ហើយនិងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងឯកសារនៃការជម្លៀសប្រជាជន និងទួលពោធិ៍ជ្រៃ*

នៅពេលអង្គជំនុំជម្រះផ្តល់ឱកាសឲ្យក្រុមការពារក្តីឆ្លើយតបទៅនឹង ការដាក់បង្ហាញឯកសាររបស់សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី មេធាវីលោក **នួន ជា** បានពន្យារពេលឆ្លើយតបជាថ្មីម្តងទៀតរហូតទាល់តែពួកគេអាចពិភាក្សាជាមួយកូនក្តីរបស់ខ្លួនបាន។ លោក **ខាណាវ៉ាស** បានលើកឡើងពីបញ្ហាសុខភាពរបស់លោក **អៀង សារី** (សូមមើល ផ្នែកទី២. ២) និងបានរម្លឹកពីការជំទាស់ទូទៅរបស់គាត់ចំពោះការប្រើប្រាស់ឯកសាររដ្ឋាភិបាល និងកំណត់ហេតុរបស់អ្នកកាសែត ដែលមិនអាចគួរឲ្យទុកចិត្តដើម្បីយកមកធ្វើជាភស្តុតាងបានទេ។ យ៉ាងណាមិញ គាត់បានសម្អាងលើបទសម្ភាសន៍ជាមួយឧត្តមសេនីយត្រី **សរ ប៊ុន** នៅស្ថានទូតបារាំងនៅក្នុងប្រទេសថៃ ដោយមិនទទួលស្គាល់លើការបន្ថែមបន្ថយរបស់ឯកអគ្គរដ្ឋទូតលើសច្ចភាពនៃសេចក្តីថ្លែងការណ៍របស់លោក **សរ ប៊ុន**។ លោក **ខាណាវ៉ាស** បានចាត់ទុកបទសម្ភាសន៍នេះ ជាពាក្យចចាមអារ៉ាមបន្តគ្នា ហើយគាត់បានកត់សម្គាល់ថា ទាំងលោកឧត្តមសេនីយត្រី និងឯកអគ្គរដ្ឋទូត មិនត្រូវបានចុះឈ្មោះជាសាក្សីសំខាន់ទេ ដូច្នេះក្រុមការពារក្តីមិនអាចសួរដេញដោល ពីសុពលភាពរបស់ឯកសារនេះបានទេ ហើយលោកបានសំណូមពរឲ្យអង្គជំនុំជម្រះច្រានចោលឯកសារនេះ ឬ យ៉ាងហោចណាស់ សូមឲ្យមានការប្រុងប្រយ័ត្នខ្ពស់បំផុតក្នុងការប្រើប្រាស់វា។ លោកក៏បានកត់សម្គាល់ដែរថា វីដេអូ "មួយថ្ងៃនៅពោធិ៍ជ្រៃ" រាប់បញ្ចូលទាំងបទសម្ភាសន៍ មិនមានសម្បថជាមួយសាក្សី ដែលគួរតែបង្ហាញមុខនៅចំពោះមុខតុលាការដើម្បីបញ្ជាក់ពីការចោទប្រកាន់របស់ពួកគេ។ ចុងក្រោយ លោក **ខាណាវ៉ាស** បានផ្តល់មតិលើសេចក្តីថ្លែងការណ៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដោយសំណូមពរអង្គជំនុំជម្រះផ្តល់ទម្ងន់ភស្តុតាងលើសេចក្តីថ្លែងការណ៍ ដែលមិនមានសម្បថនេះឲ្យបានត្រឹមត្រូវ។ មេធាវី **ហ្គីសសេ** តំណាងឲ្យលោក **ខៀវ សំផន** បានយល់ស្របនឹងសេចក្តីជំទាស់របស់លោក **ខាណាវ៉ាស** ដោយរម្លឹកពីសេចក្តី

សម្រេចរបស់តុលាការដំបូងទាក់ទងនឹងទម្ងន់ភស្តុតាង ដែលបានមកពីបុគ្គលដែលមិនបានមកធ្វើសក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ។ កញ្ញា ក៏បានបន្តធ្វើការកត់សម្គាល់ឃើញថា លោក **វេយ័ន័រ** បានដាក់បង្ហាញឯកសារ និងវីដេអូឃ្លីបដោយស្ទាត់ជំនាញ តែអ្នកដែលជាប់ពាក់ព័ន្ធនឹងសេចក្តីថ្លែងការណ៍ទាំងនោះមិនដែលមានភាពច្បាស់លាស់ទេ។ កញ្ញាបានឲ្យដឹងថា ការកាត់តវីដេអូឃ្លីបបែបនេះមិនត្រឹមត្រូវតាមច្បាប់តុលាការទេ ដោយសារតែរូបភាពត្រូវបានធ្វើឡើងក្នុងស្ថានការណ៍គ្មានប្រភពច្បាស់លាស់ ដែលតម្រូវឲ្យមានតែការយល់ឃើញផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ កញ្ញា **ហ្គីសសេ** បានបញ្ចប់ដោយបម្រុងទុកសិទ្ធិធ្វើការកត់សម្គាល់បន្ថែមទៀត ប្រសិនបើកូនក្តីរបស់កញ្ញា គឺលោក **ខៀវ សំផន** ចង់បន្ថែមអ្វីផ្សេងទៀត។

លោក **វេយ័ន័រ** បានអរគុណ កញ្ញា **ហ្គីសសេ** សម្រាប់ពាក្យគួរសម ដោយទទួលស្គាល់ថា ពួកអ្នកនោះមិនមែនជាលោក **ស្ទេវិន ស្ពៀលប៊ឺក** (*Mr. Steven Spielberg*) ប៉ុន្តែ ពួកអាចជូនព័ត៌មានដល់អង្គជំនុំជម្រះបាន។[93] បន្ទាប់មក លោកក៏បានឆ្លើយតបទៅនឹងសេចក្តីជំទាស់ដោយសង្កត់ធ្ងន់ទៅលើភាពខុសគ្នារវាង ការទទួលស្គាល់ឯកសារ និងទម្ងន់ភស្តុតាង។ ចំពោះរបាយការណ៍លើបទសម្ភាសន៍ **សរ ប៊ុន** វិញ លោក **វេយ័ន័រ** បានទទូចឲ្យអង្គជំនុំជម្រះក្រលេកមើលភស្តុតាងស៊ីចង្វាក់គ្នាផ្សេងទៀត ដើម្បីកំណត់ថា តើវាមានសារៈសំខាន់ដែរឬទេ។ លោកព្រះរាជអាជ្ញា បានផ្តល់យោបល់ថា សាក្សីអាចពន្យល់វីដេអូឃ្លីបខ្លះៗ ជាពិសេស អ្នកថតរូប គឺលោក **អាល់ រុកកូហ្វ** (*Mr. Al Rockoff*) ជាសាក្សីដែលអាចនឹងកោះហៅមកពន្យល់ពីរូបភាពមន្ត្រីរាជការ **លន់ នល់** ដ៏គួរឲ្យចាប់អារម្មណ៍របស់គាត់នៅថ្ងៃ១៧ មេសា ១៩៧៥។ បន្ទាប់មក លោក **ពេជ អង្គ** បានសំណូមពរឲ្យក្រុមមេធាវីការពារក្តីអាចចាត់តាំងសាក្សីដែលមានព័ត៌មានស៊ីចង្វាក់នឹងឯកសារ ជាសាក្សីមានសារៈសំខាន់ចំពោះពួកគេសម្រាប់ធ្វើការសួរដេញដោល។ លោកស្រី **អេលីហ្សាបេត ស៊ីម៉ុនណូហ្វត** បានសម្តែងភាពក្រោធរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងការចែកថ្នាក់នៃសេចក្តីថ្លែងការណ៍របស់ជនរងគ្រោះរបស់លោក **ខាណាវ៉ាស** ថាជាសេចក្តីថ្លែងការណ៍គ្មានសម្បថ ដោយសារអង្គជំនុំជម្រះបានធ្វើសេចក្តីសម្រេចរួចហើយលើបញ្ហានេះ ហើយកង្វះខាតពាក្យសម្បថរបស់ពួកគេ មិនអាចដកចេញតម្លៃភស្តុតាងបឋមនៃសេចក្តីថ្លែងការណ៍របស់ពួកគេបានឡើយ។

ជាដំបូង លោក **ខាណាវ៉ាស** បានឆ្លើយតបទៅលោក **ពេជ អង្គ** ដោយពន្យល់ថា ក្រុមការពារក្តីមិនមានបន្ទុកនៃការបង្ហាញភស្តុតាងទេ។ ដូច្នេះ ពួកគេមិនមានកាតព្វកិច្ចណាមួយក្នុងការកោះហៅសាក្សី ប៉ុន្តែគាត់បានសំណូមពរឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណី កោះហៅដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធ សម្រាប់ធ្វើការសួរដេញដោលដើម្បីដាក់ទម្ងន់ភស្តុតាងឲ្យខ្លាំង។ ជាកិច្ចឆ្លើយតបទៅលោក **វេយ័ន័រ** លោក **ខាណាវ៉ាស** បានយល់ស្របថា វាមានភាពខុសគ្នារវាងការទទួលស្គាល់ភស្តុតាង និងតម្លៃភស្តុតាងបឋម ហើយក្នុងការឆ្លើយតបទៅនឹងលោកស្រី **ស៊ីម៉ុនណូហ្វត** លោក **ខាណាវ៉ាស** បានរម្លឹកលោកស្រីថា គាត់ត្រូវបានស្នើសុំឲ្យផ្តល់មតិយោបល់ ហើយគាត់គ្រាន់តែនិយាយឡើងវិញ ពីការពិតនៃជីវិត ដែលថាអង្គជំនុំជម្រះគួរតែឲ្យតម្លៃភស្តុតាងលើសេចក្តីថ្លែងការណ៍ណាដែលមិនមានសម្បថតិច ជាងសេចក្តីថ្លែងការណ៍ដែលមានសម្បថ។ យ៉ាងណាមិញ លោក **ខាណាវ៉ាស** បាន

បញ្ជាក់ថា គាត់មិនដែលបានចោទថា ដើមបណ្តឹងរដ្ឋប្បវេណីនិយាយកុហកទេ ប៉ុន្តែ អវត្តមានរបស់ពួកគេបានបណ្តាលឲ្យក្រុមការពារក្តីក្នុងស្ថានការណ៍ខាតប្រយោជន៍យ៉ាងខ្លាំង។ បន្ទាប់មក លោកចៅក្រម បានពិភាក្សាគ្នា ហើយចៅក្រម **ខាត់វ៉ាយច៍** បានថ្លែងថា បញ្ហាដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីថ្លែងការណ៍គ្មានសម្បថត្រូវបានពិភាក្សាកន្លងមកហើយ ហើយអង្គជំនុំជម្រះបានយល់ដឹងពេញលេញពីទំនួលខុសត្រូវរបស់ខ្លួនទាក់ទងនឹងការឲ្យតម្លៃភស្តុតាង ដោយមិនចាំបាច់លើកឡើងពីបញ្ហានេះម្តងហើយម្តងទៀតទេ។[94]

## ផ្នែកទី៣៖ បញ្ហានីតិវិធី និង ច្បាប់

ក្រៅពីការដាក់បង្ហាញឯកសារ និងស្តាប់ការឆ្លើយឆ្លងមតិរវាងភាគីទាំងអស់ហើយ កិច្ចដំណើរការនីតិវិធីនាសប្តាហ៍នេះ ក៏បានលើកឡើងពីបញ្ហានីតិវិធីសមស្របទាក់ទងនឹងភស្តុតាងឯកសារ និងស្ថានភាពសុខភាពរបស់លោក **អៀង សារី**។

### ១. ការភ័ន្តច្រឡំលើនីតិវិធីដែលអាចយកអនុវត្តបាន

សញ្ញាទីមួយនៃការភ័ន្តច្រឡំលើនីតិវិធីសវនាការដែលអាចអនុវត្តបាន ត្រូវបានស្តែងឡើងតាំងពីដើមសប្តាហ៍ នៅពេលដែលព្រះរាជអាជ្ញា **វាយដ៍ ដេស្មាឯល** បានលើកសំណើផែនការលើរបៀបរបបនៃការធ្វើបទបង្ហាញឯកសារក្នុងសប្តាហ៍នោះ ជាពិសេស អំពីឯកសារមាននៅក្នុងឧបសម្ព័ន្ធ១ នៃសំណើដើមរបស់សហព្រះរាជអាជ្ញា។[95] អង្គជំនុំជម្រះ បានធ្វើការពិភាក្សាគ្នា ហើយទីបំផុតព្រមទទួលយកសំណើនេះ។ លោក **ខាណាវ៉ាស** បានសម្តែងភាពភ្ញាក់ផ្អើលដែលអង្គជំនុំជម្រះបានទទួលយកសំណើរបស់សហព្រះរាជអាជ្ញាលើនីតិវិធីដែលអាចអនុវត្តបាន ដោយសារគាត់បានដឹងតាមរយៈអ៊ីមែលឆ្លើយឆ្លងគ្នាជាច្រើនថា ភាគីទាំងអស់នឹងត្រូវបានរំពឹងឲ្យដាក់សំណើជាលាយលក្ខណ៍អក្សរលើឯកសារទាំងអស់។

ដំបូងឡើយ នៅពេលដែលលោក **ខាណាវ៉ាស** បានលើកយកបញ្ហាសំណើជាលាយលក្ខណ៍អក្សរ លោក **វ៉ាយដ៍ ដេស្មាឯល** បានជំទាស់ថា វានឹងពន្យារពេលនីតិវិធី ហើយទស្សនៈនេះត្រូវបានគាំទ្រដោយលោកស្រី **ស៊ីម៉ុនណូហ្សត**។ លោក **ខាណាវ៉ាស** បានឆ្លើយតបភ្លាមៗដោយទាមទារឲ្យអង្គជំនុំជម្រះបញ្ជាក់ឲ្យច្បាស់ពីនីតិវិធី ជាពិសេស សំណើជាលាយលក្ខណ៍អក្សរ មិនដែលជួបឧបសគ្គទេកន្លងមក។ មេធាវីលោក **ខៀវ សំផន** និង **នួន ជា** បានគាំទ្រលើមតិនេះ ហើយយោងទៅលើអនុស្សរណៈរបស់អង្គជំនុំជម្រះនៅថ្ងៃទី១៦ ខែមករា ដែលអនុញ្ញាតឲ្យក្រុមការពារក្តីដាក់សំណើបន្ថែមលើឯកសារ ក្រោយពីបានប្រឹក្សាយោបល់ជាមួយកូនក្តីរបស់ពួកគេ។ បន្ទាប់មក ចៅក្រម **ស៊ីលវៀ ខាត់វ៉ាយច៍** បានពន្យល់ថា អង្គជំនុំជម្រះនៃតុលាការដំបូងនឹងណែនាំក្រុម ទាំងពីពីថេរវេលានិងវិធីដាក់សំណើនាពេលក្រោយ។ យ៉ាងណាមិញ ការប្រើប្រាស់សំណើជាលាយលក្ខណ៍អក្សររបស់ក្រុមមេធាវីការពារក្តីឲ្យលោក **អៀង សារី** នៅតែមិនទាន់បានដោះស្រាយរហូតដល់ លោកស្រី **ស៊ីម៉ុនណូហ្សត** និងលោក **ខា**

**ណាវ៉ាស** បានសួរបញ្ជាក់លើបញ្ហានេះ។ ក្រោយពីបានសម្រាកយូរបន្តិចនៅរសៀលថ្ងៃអង្គារ ចៅក្រម **ខាតវ៉ាយច៍** បានពន្យល់ថា សំណើជាលាយលក្ខណ៍អក្សរអាចទទួលយកបាន ឲ្យតែសំណើទាំងនេះដាក់ឲ្យទាន់កាលបរិច្ឆេទដែលបានកំណត់។ លោកស្រីចៅក្រម ក៏បានទុកពេលវេលាឲ្យក្រុមលោក **ខៀវ សំផន** និង **នួន ជា** រហូតដល់ចុងសប្តាហ៍ក្រោយដើម្បីដាក់សំណើជំទាស់តវ៉ាទាក់ទងនឹងការទទួលស្គាល់ឯកសារឧបសម្ព័ន្ធ១ និងស្នើសុំឲ្យភាគីទាំងអស់ឲ្យផ្តល់ការឆ្លើយតបទៅកាន់សំណើរបស់ពួកគេនៅត្រឹមថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ហើយនៅក្រោយកាលបរិច្ឆេទនេះ តុលាការនឹងចេញសេចក្តីសម្រេចមួយលើការទទួលយកបាននៃឯកសារ។

កញ្ញា **ហ្គីសសេ** ក៏បានសួរថាហេតុអ្វីបានជាក្រុមការពារក្តីត្រូវបានស្នើឲ្យលើកពីបញ្ហាការទទួលយកបាននៃឯកសារទៅវិញ ព្រោះកញ្ញាជឿជាក់ថាគោលបំណងចម្បងនៃសវនាការនេះ បានចែងក្នុងអនុស្សរណៈ ចុះថ្ងៃទី១៦ ខែមករា គឺដើម្បីជូនព័ត៌មានដល់សាធារណជន និងផ្តល់ឱកាសឲ្យជនជាប់ចោទផ្តល់មតិយោបល់។ ចៅក្រម **ខាតវ៉ាយច៍** បានបញ្ជាក់ថា គោលបំណងនៃសវនាការនេះទាក់ទងនឹងការដាក់បង្ហាញឯកសារពាក់ព័ន្ធ នឹងផ្នែកជាក់លាក់នៃរឿងក្តីនេះ ដើម្បីអនុញ្ញាតឲ្យភាគីទាំងអស់បញ្ជាក់លើឯកសារណាដែលមានខ្លួនយល់ថាសំខាន់ខ្លាំងចំពោះសំណុំរឿងរបស់ខ្លួន និងដើម្បីធានាឲ្យសាធារណជនអាចទទួលបានព័ត៌មាន និងដឹងលឺចំពោះឯកសារដែលនឹងត្រូវប្រើប្រាស់ក្នុងសំណុំរឿងនេះ។ បន្ទាប់ពីមានការបញ្ជាក់របស់អង្គជំនុំជម្រះនៅថ្ងៃទីពីរមក កិច្ចដំណើរនីតិវិធីបន្តពីនេះ ក៏មានប្រសិទ្ធភាពជាងមុន។

## ២. សុខភាព និងសម្បទារបស់លោក អៀង សារី ក្នុងការជំនុំជម្រះ

នៅថ្ងៃពុធ លោក **ខាណាវ៉ាស** បានលើកបញ្ហាសុខភាពផ្លូវចិត្តរបស់កូនក្តីខ្លួនជាថ្មីម្តងទៀត ដោយកត់សម្គាល់ឃើញពីការសួរសុខទុក្ខកូនក្តីរបស់គាត់ នៅបន្ទប់ឃុំឃាំងតាមដានសវនាការក្នុងអំឡុងវគ្គសវនាការពេលព្រឹក។ គាត់បានពន្យល់ថា សញ្ញារបស់ជនជាប់ចោទអាចទទួលយកបាន ប៉ុន្តែគាត់មិនអាចតាមដាននីតិវិធីសវនាការបានទេ។ គាត់បានបន្តយល់ថា របាយការណ៍វេជ្ជបណ្ឌិតពីបន្ទប់ឃុំឃាំងតាមដានសវនាការ ថាជាការមិនសមហេតុផល ដោយសារតែមានសញ្ញាគិតថា មានលទ្ធភាពតាមដាននីតិវិធីសវនាការបាន។ យ៉ាងណាមិញ លោក **ខាណាវ៉ាស** ក៏បានពន្យល់ដែរថា ពេលគាត់បានសួរ ថាតើ **អៀង សារី** ចង់លះបង់សិទ្ធិមិនមានវត្តមានក្នុងកិច្ចដំណើរការសវនាការដែរ ឬទេ ? កូនក្តីរបស់គាត់បានឆ្លើយតបវិញថា គាត់មិនប្រកាន់នៅបន្ទប់ឃុំឃាំងតាមដានសវនាការខាងក្រោមទេ។ មុននឹងបន្តការដាក់បង្ហាញឯកសារ លោក វេយ៍ន័រ បានឆ្លើយតបទៅវិញថា គោលជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហានេះមិនមានការផ្លាស់ប្តូរទេ ហើយអង្គជំនុំជម្រះគួរតែទទួលបានព័ត៌មានគ្រប់គ្រាន់លើបញ្ហានេះ។ មុននឹងសម្រាកអាហារថ្ងៃត្រង់ ចៅក្រម **ខាតវ៉ាយច៍** បានកត់សម្គាល់ពីការលះបង់សិទ្ធិរបស់លោក **អៀង សារី** ក្នុងការចូលរួមសវនាការ និងបានបង្គាប់ឲ្យវេជ្ជបណ្ឌិតផ្តល់នូវរបាយការណ៍សុខភាពរបស់លោក **អៀង សារី** ឲ្យបានមុនថ្ងៃឈប់សម្រាកសវនាការ។

លោក **ខាណាវ៉ាស** បានលើកបញ្ហានេះម្ដងទៀតនៅថ្ងៃបន្ទាប់ ដោយអះអាងថា តួនាទីរបស់វេជ្ជបណ្ឌិតមិនបានឆ្លើយតបនឹងសំណួររបស់អ្នកគ្រប់គ្រងសំណុំរឿងរបស់លោក **អៀង សារី** លើលទ្ធភាពរបស់ជនជាប់ចោទក្នុងការតាមដានកិច្ចដំណើរការនីតិវិធីទេ។ លោក វេជ្ជបណ្ឌិត បានប្រាប់អ្នកគ្រប់គ្រងសំណុំរឿងថា គាត់មិនអាចផ្ដល់ការវាយតម្លៃបានទេ ដោយសារតែគាត់ត្រូវតែទាក់ទង "ក្រុមការងារ" ដើម្បីពិភាក្សាពីអ្វីដែលត្រូវដាក់ក្នុងរបាយការណ៍សុខភាព។ លោក **ខាណាវ៉ាស** បានសង្កេតថា វេជ្ជបណ្ឌិតបែបនេះ មិនអាចធ្វើការសង្កេតសុខភាពដោយខ្លួនគាត់បាន ហើយវាស្ដែងឲ្យឃើញពីមុសាវាទ ឬ ភាពក្លែងក្លាយសុទ្ធសាធ ហើយគាត់សំណូមពរឲ្យវេជ្ជបណ្ឌិតមានលទ្ធភាពធ្វើរបាយការណ៍សុខភាព។ លោក **ពេជ អង្គ** បានចោទសួរពីភាពសមរម្យនៃធ្វើមតិរបស់លោក **ខាណាវ៉ាស** បែបនេះ។ អង្គជំនុំជម្រះ តំណាងដោយចៅក្រម **ខាតវ៉ាយថ៍** បានធ្វើរិះគន់ដល់លោក **ខាណាវ៉ាស** ដោយសារហេតុផលទីមួយ គឺវាគ្មានប្រយោជន៍ទាល់តែសោះសម្រាប់បុគ្គលពេទ្យមិនស្គាល់ជំនាញ ឬ មេធាវីដាក់គំនាបសង្កត់លើវេជ្ជបណ្ឌិត ដោយសារតែវេជ្ជបណ្ឌិតស្ថិតនៅក្រោមការណែនាំឲ្យរាយការណ៍ជូនអង្គជំនុំជម្រះតែម្នាក់គត់ ហើយហេតុផលទី២ សម្រាប់ការប្រើប្រាស់ពាក្យ មុសាវាទ ដែលផ្ដែផ្ដាឲ្យវេជ្ជបណ្ឌិតថាបាននិយាយកុហក ដែលជាមតិមួយដែលចៅក្រម **ខាតវ៉ាយថ៍** បានស្ដីបន្ទោសថា ជាសេចក្ដីថ្លែងការណ៍មិនសមរម្យប្រើប្រាស់ក្នុងតុលាការ។

## ផ្នែកទី៤៖ ការគ្រប់គ្រងសវនាការ

ខណៈ **នួន ជា** និង **ខៀវ សំផន** មិនអាចចូលរួមកិច្ចដំណើរការនីតិវិធីបានក្នុងសប្ដាហ៍នេះ ដោយសារតែការព្យាបាលជម្ងឺនៅមន្ទីរពេទ្យ អង្គជំនុំជម្រះបានបើកសវនាការលើឯកសារមុនកាលវិភាគដែលបានគ្រោង ដែលបានកំណត់នៅខែកុម្ភៈ ឆ្នាំ២០១៣ ជំនួសសវនាការលើសក្ខីកម្មសាក្សីវិញ។ អង្គជំនុំជម្រះ បានបន្តខ្នះខ្នែងធានាឲ្យមានប្រសិទ្ធភាពនៃនីតិវិធីសវនាការពេញមួយសប្ដាហ៍ និងបានសួរ ថាតើសហព្រះរាជអាជ្ញាអាចដាក់បង្ហាញឯកសារលើប្រធានបទបន្ថែមទៀតបានដែរឬទេ? សហព្រះរាជអាជ្ញា បានពន្យល់ដល់អង្គជំនុំជម្រះថា សហព្រះរាជអាជ្ញាអាចធ្វើបទបង្ហាញឯកសារលើតួនាទីរបស់ជនជាប់តែប៉ុណ្ណោះនៅសប្ដាហ៍ក្រោយ ហើយនឹងមានបំណងដាក់បង្ហាញឯកសារលើសហឧក្រិដ្ឋកម្មនៅពេលខាងមុខទៀត។ អង្គជំនុំជម្រះបានព្រមានភាគីទាំងអស់ឲ្យត្រៀមខ្លួនចេះបត់បែនតាមកាលវិភាគភ្លាមៗនៅប៉ុន្មានសប្ដាហ៍ខាងមុខ ដែលបូកបញ្ចូលសក្ខីកម្មសាក្សី (TCW-565) ហើយនិងក្នុងករណីលោក **នួន ជា** ជ្រើសរើសមិនបោះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់តុលាការ។

### ក. វត្តមាន

ជនជាប់ចោទទាំងបីនាក់ មិនមានវត្តមានក្នុងបន្ទប់សវនាការទេ ដោយសារបញ្ហាសុខភាពទន់ខ្សោយ។ លោក **ខៀវ សំផន** និងលោក **នួន ជា** បានសម្រាកនៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-រុស្ស៊ី ហើយលោក **អៀង សារី** បានតាមដានសវនាការពីបន្ទប់ឃុំឃាំងនៅខាងក្រោម។

**វត្តមានដើមបណ្តឹងរដ្ឋប្បវេណី៖** នៅសប្តាហ៍នេះ ដើមបណ្តឹងរដ្ឋប្បវេណី១៥នាក់ បានចូលរួមតាមដានកិច្ចដំណើរការនីតិវិធីសវនាការរាល់ថ្ងៃ។ មាន១០នាក់បានអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ និង៥នាក់ទៀតបានតាមដានពីសាលសវនាការសាធារណៈ។

**វត្តមានភាគី៖** ភាគីតំណាងទាំងអស់ គឺមានវត្តមានក្នុងបន្ទប់សវនាការ។ លោក **សុន អរុណ** មេធាវីជាតិការពារក្តីឲ្យលោក **នួន ជា** បានចាកចេញពីបន្ទប់សវនាការនៅរសៀលថ្ងៃ ពុធ និងវគ្គសវនាការទី២ និងទី៣នៅថ្ងៃព្រហស្បតិ៍។ តុលាការមិនបានប្រកាសពីអវត្តមានរបស់គាត់ទេ។

**វត្តមានសាធារណជន៖**

| កាលបរិច្ឆេទ | សវនាការពេលព្រឹក | សវនាការពេលរសៀល |
|---|---|---|
| ថ្ងៃចន្ទ ២១/០១/១៣ | ▪ អ្នកភូមិ៤៧០នាក់ មកពីឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ<br>▪ ក្រុមនិស្សិតជប៉ុនមួយក្រុមមាន១៥នាក់<br>▪ អ្នកសង្កេតការណ៍បរទេស ២ នាក់ | ▪ អ្នកភូមិ៣០នាក់ មកពីស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល<br>▪ អ្នកសង្កេតការណ៍បរទេស ៤ នាក់ |
